សមិទ្ធិផលបន្តិចបន្តួចដូចជាសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពានប្រឡាយទឹក...
ដែលបានមកពីការសេពគប់ជាមួយឈ្មួញទុច្ចរិត និងការកេងប្រវ័ញ្ចធនធានជាតិរបស់
គណបក្សកុម្មុយនីស្តតាមពិតទៅពុំមែនជាចេតនាល្អចង់អភិវឌ្ឍន៍ស្អីនោះទេ...តែផ្ទុយ
មកវិញសមិទ្ធិផលទាំងនោះ វាគ្រាន់តែជាការសងថ្លៃខូចខាតដែលគណបក្សនេះ
បានសហការជាមួយយួនបំផ្លិចបំផ្លាញកម្ពុជាជាង ១០ ឆ្នាំ ប៉ុណ្ណោះ...

# ព្រឹត្តិបត្រសមាគមនិស្សិតខ្មែរ

# Khmer Students Association Newsletter

ឆ្នាំទី៤ លេខ០៣៣ ខែ កក្កដា_សីហា ឆ្នាំ ១៩៩៦

អាសយដ្ឋានលេខ៧៥ វិថីលេខ១១៨ សង្កាត់ទឹកល្អក់ពីរ ខណ្ឌទួលគោក ក្រុងភ្នំពេញ

ទូរស័ព្ទលេខ : (855) 23 366656, (015) 914 332

ទូរសារលេខ : (855)23 366656

## មាតិកាអត្ថបទ

- បទវិចារណកថា : គ្រោះថ្នាក់នៃអាយ៉ងទាំងពីរ
- បរិយាយខែនេះ : មិនមែនជាការអភិវឌ្ឍន៍ទេ វាគឺជាសំណងថ្លៃបំផ្លិចបំផ្លាញ
- ទស្សនៈនិស្សិត : ប្រជាប្រិយភាពដែលបានមកពីអំពើថោកទាប
  : នយោបាយលាបពណ៌របស់អ្នកនយោបាយ
- ចេតិកានារី : ឧត្តមគតិអ្នកសារព័ត៌មានខ្មែរបច្ចុប្បន្ន
- លិខិតមិត្តអ្នកអាន : សេចក្តីព្រួយបារម្ភចំពោះលទ្ធផលនៃការកែសម្រួល
  ច្បាប់ស្តីពីកងយោធពលខេមរភូមិន្ទ
  : ខ្មែរក្រហមបែកពីក្រុម ប្រសព្វគ្នាវិញហើយ
- ស្តាប់និស្សិតស្រែក : បញ្ហាចាស់ដែលមិនទាន់ដោះស្រាយ
- ជ្រុងមួយនៃសង្គម : អសន្តិសុខ និងអនាធិបតេយ្យក្នុងក្រុងភ្នំពេញ
- អត្ថបទស្រាវជ្រាវ :
- ទំព័រកំណាព្យ : ត្រកួន កញ្ឆែត !

ចែកជូនដោយឥតគិតថ្លៃ

បទវិចារណកថា :

# គ្រោះថ្នាក់នៃអាយ៉ងទាំងពីរ

ដោយអ៊ុន ម៉ូរីខ

ស្ថិតក្នុងភាពប្រទាញប្រទង់គ្នាដើម្បីបានទទួលបានការគាំទ្រពីប្រជារាស្ត្រចំពោះនយោបាយរបស់ខ្លួនក្នុងការដឹកនាំជាតិកន្លងមក ជាពិសេសបច្ចុប្បន្នអ្នកនយោបាយតែងយកបញ្ហាយួន និងខ្មែរក្រហមដែលជាអ្នកមានកំហុសជាលក្ខណៈប្រវត្តិសាស្ត្រសំរាប់ជាតិ និងប្រជារាស្ត្រខ្មែរមកធ្វើជាមធ្យោបាយចោទប្រកាន់គ្នា ។ ដោយសារយួន និងខ្មែរក្រហម ធ្លាប់បានផ្តល់នូវការអាម៉ាស់ ការឈឺចាប់ខ្លោចផ្សារ និងសេចក្តីភ័យខ្លាចឥតឧបមា បានធ្វើឱ្យប្រជារាស្ត្រខ្មែរថ្កោលទោស ចងគំនុំចំពោះគេ (យួន_ខ្មែរក្រហម) គ្មានថ្ងៃបំភ្លេច ។

នយោបាយយូរអង្វែងរបស់យួនក្នុងការបន្តលេបយកទឹកដីខ្មែរ បន្ទាប់ពីប្លន់យកបានដីកម្ពុជាក្រោម និងការប៉ុនប៉ងយ៉ាងយកចិត្តទុកដាក់របស់ខ្មែរក្រហមក្នុងការវិលត្រលប់មកកាន់អំណាចនៅកម្ពុជាជាលើកទីពីរក្រោយពីរបបខ្លួនត្រូវបានផ្តួលរំលំដោយយួន និងខ្មែរលក់ក្បាលឱ្យយួនមួយក្រុមបានបង្កើតនូវក្តីកង្វល់យ៉ាងខ្លាំងក្លាចំពោះអ្នកស្នេហាជាតិ និងប្រជារាស្ត្រខ្មែរស្លូតត្រង់ ។ ម្ល៉ោះហើយដើម្បីបានការគាំទ្រ ក្តីកង្វល់របស់ប្រជារាស្ត្រចំពោះបញ្ហាយួន និងខ្មែរក្រហម ត្រូវបានអ្នកនយោបាយគ្រប់ប្រភេទ ពិសេសគណបក្សធំៗទោះចង់ ឬមិនចង់ក៏ត្រូវធ្វើការសំរេចចិត្តជ្រើសរើសយកបញ្ហាយួន និងខ្មែរក្រហមមកធ្វើជាអាទិភាពនៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន ។

ក្នុងការឃោសនារកសំលេងឆ្នោតពីប្រជារាស្ត្រពាក្យអាយ៉ងយួន និងអាយ៉ងខ្មែរក្រហមត្រូវបានអ្នកនយោបាយយកមកប្រើប្រាស់គ្រប់ពេលគ្រប់វេលា រហូតពាក្យពីរម៉ាត់នេះបានក្លាយទៅជាពាក្យប្រជាប្រិយវិស័យនយោបាយទៅហើយ ។ ការខ្វះមធ្យោបាយ ខ្វះពេលវេលា និងដោយសារការបំពុលស្មារតីអារម្មណ៍ ការបំភ្លៃរបស់អ្នកនយោបាយបានធ្វើឱ្យលទ្ធផលនៃការវិភាគពិចារណា និងការសំរេចចិត្តរបស់ប្រជារាស្ត្រខ្មែរ ស្តីពីបញ្ហាគ្រោះថ្នាក់ដែលផ្តល់ឱ្យដោយយួន និងខ្មែរក្រហមស្ថិតក្នុងភាពស្រពិចស្រពិល ។ ហេតុនេះហើយទើបអ្នកនយោបាយដែលបានជ្រើសរើសកម្មវិធីនយោបាយដេញយួនទៅស្រុកវិញ និងប្រឆាំងដាច់ខាតការវិលត្រលប់មកវិញជាលើកទីពីរនៃរបបខ្មែរក្រហមប៉ុលពតនៅតែបានទទួលជោគជ័យក្នុងការគាំទ្រពីប្រជារាស្ត្រក្នុងកំរិតខ្ពស់ដដែល ។

ដោយសារគណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច ដែលធ្លាប់តែដេកព្រៃជាមួយសត្វស្វា ធ្លាប់ផឹកទឹកភក់ ធ្លាប់យកដីធ្វើជាគ្រែ យកគល់ឈើ និងដុំថ្មធ្វើជាខ្នើយ ម្ល៉ោះហើយលុះបានអំណាច និងស្គាល់រសជាតិសំភារៈទំនើបៗក៏ល្អក់វង្វេងឡប់ស្មារតីអស់ទៅ ។ ដោយសារបញ្ហានេះហើយ ទើបអំណាចដឹកនាំប្រទេសសព្វថ្ងៃនេះត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃគណបក្សប្រជាជនកម្ពុជាស្ទើរទាំងអស់ ។ ដោយសារពីអតីតកាល និងបច្ចុប្បន្នយួនហានួយនៅតែត្រូវបានគណបក្សកុម្មុយនីស្តនេះ ចាត់ទុកជាចៅហ្វាយនាយ ហេតុនេះហើយទើបអ្នកនយោបាយស្នេហាជាតិ និងប្រជារាស្ត្រស្រលាញ់សន្តិភាព_សេរីភាព ហើយប្រឆាំងការឈ្លានពានរបស់យួន ដែលត្រូវបានចោទប្រកាន់ថាជាខ្មែរក្រហម ឬជាអាយ៉ងខ្មែរក្រហម (តាមពិតមិនមែនខ្មែរក្រហម) ត្រូវទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរ ។

ផ្ទុយមកវិញ ក្រុមមនុស្សដែលមិនមែនត្រឹមតែជាអាយ៉ងយួនប៉ុណ្ណោះទេ តែធាតុពិតវាគឺជាយួនសុទ្ធសាធ ហើយដែលកំពុងធ្វើនយោបាយឈ្លានពានយកទឹកដីកម្ពុជាដោយចំហរ ដែលត្រូវបានប្រជារាស្ត្រធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការ បែរជាត្រូវបានគណបក្សកុំមុយនីស្តដែលកំពុងកាន់អំណាចសព្វថ្ងៃនេះ ប្តេជ្ញាការពារយ៉ាងមុឹងម៉ាត់ទៅវិញ ។ តើប្រជារាស្ត្រយើងមានឆ្ងល់ទេ ហេតុអីខ្មែរក្រហមដែលជាខ្មែរត្រូវទទួលរងគ្រោះ តែយួនដែលជាជនជាតិបរទេសបែរជាត្រូវបានគណបក្សកុំមុយនីស្តមួយនេះការពារទៅវិញ ? តើគណបក្សនេះបំរើផលប្រយោជន៍យួនឬមួយក៏បំរើផលប្រយោជន៍ឱ្យខ្មែរ ? តើធាតុពិតយួន ឬអាយ៉ងយួន និងខ្មែរក្រហម ឬអាយ៉ងខ្មែរក្រហមមួយណាដែលផ្តល់គ្រោះថ្នាក់សំរាប់ជាតិ និងប្រជារាស្ត្រខ្លាំងជាងគេ ?

ពិតមែនហើយថាខ្មែរក្រហម និងយួនសុទ្ធតែជាប្រភពផ្តល់គ្រោះថ្នាក់ដល់ជាតិ និងប្រជារាស្ត្រខ្មែរដូចគ្នាពោលគឺយួនធ្លាប់បានឆក់ប្លន់យកទឹកដីកម្ពុជាក្រោមដែលមានដីទំហំស្មើរប៉ុនស្រុកខ្មែរសព្វថ្ងៃ យួនធ្លាប់យកក្បាលខ្មែរទៅដាំតែអុង ។ ក្រោយឆ្នាំ១៩៧៩ យួនចូលមកលុកលុយឈ្លានពានលេបយកទឹកដីខ្មែរសារជាថ្មីម្តងទៀត ។ គឺពេលនោះហើយ ដែលយួនបានបញ្ជូនជនជាតិវាឱ្យចូលមករស់នៅស្រុកខ្មែររាប់សិបសែននាក់ ហើយធ្វើការឆក់ប្លន់ទ្រព្យសម្បត្តិខ្មែរសព្វសារពើ និងបានធ្វើឱ្យរចនាសម្ព័ន្ធក្នុងសង្គមខ្មែរតាំងជាង ១០ ឆ្នាំ ។ ជាពិសេសយួនបានសំលាប់ខ្មែរ បានធ្វើឱ្យរាស្ត្រខ្មែរក្លាយជាស្ត្រីមេម៉ាយ ជនពិការ កុមារកំព្រា...។ រីឯខ្មែរក្រហមក៏ដូចគ្នាក្នុងអំឡុងពេលកាន់អំណាចជាងបីឆ្នាំខ្លួនបានសំលាប់ប្រជាជនឯងអស់ ជិតពីរលាននាក់តាមរូបភាពសាហាវឃោរឃៅរកអ្វីប្រៀបផ្ទឹមពុំបាន ។ ក្រៅពីបានបំផ្លាញជីវិតមនុស្ស ខ្មែរក្រហមនៅបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធជាតិ និងធនធានគ្រប់ប្រភេទរបស់ខ្មែរច្រើនរាប់មិនអស់ ។

ប៉ុន្តែទោះជាយ៉ាងណាក្តី បើយើងធ្វើការវិភាគវាយតំលៃ ដោយឈរលើសច្ចៈភាព និងគោលគំនិតជាតិនិយមតាមទស្សនៈ "គ្មានអ្នកណាស្រលាញ់ខ្មែរ ជាងខ្មែរស្រលាញ់ខ្មែរ" នោះយើងនឹងយល់ថាយួនវាពិតជាប្រភពផ្តល់គ្រោះថ្នាក់ដ៏សែនធ្ងន់ធ្ងរបំផុតសំរាប់ជាតិ និងប្រជារាស្ត្រខ្មែរ ។ ហើយគ្រោះថ្នាក់ដែលខ្មែរបានទទួលពីយួនធំធេងជាងគេនោះ គឺការបាត់បង់ទឹកដីខ្មែរបច្ចុប្បន្ននេះ ។ ព្រោះថាមកដល់សម័យនេះទៅហើយការសំលាប់រង្គាល ឬមួយក៏របបប្រល័យពូជសាសន៍ឯងស្អីគេនោះវាដូចជាហួសសម័យទៅហើយ ។ តែផ្ទុយមកវិញអ្វីដែលវាទាន់សម័យបំផុត ហើយដែលនៅលើពិភពលោកកំពុងជួបប្រទះរហូតមកដល់ពេលនេះ គឺជំលោះព្រំដែន ដែលធាតុពិតយួនវាកំពុងតែអនុវត្តន៍មកលើប្រទេសយើងសព្វថ្ងៃនេះឯង ។

ហេតុនេះសូមប្រជារាស្ត្រខ្មែរប្រុងប្រយ័ត្នឱ្យមែនទែន គ្រោះថ្នាក់ដែលខ្មែរបានទទួល កំពុងទទួល និងបន្តការទទួលតទៅទៀតក្នុងកំរិតធ្ងន់ធ្ងរបំផុត និងគ្មានថ្ងៃបញ្ចប់នោះ ពុំមែនខ្មែរក្រហមដែលជាខ្មែរទេ គឺជាយួន ។ ដូចនេះមានន័យថា ធាតុពិតនៃប្រភពគ្រោះថ្នាក់សំរាប់កម្ពុជាក្នុងពេលបច្ចុប្បន្ន និងអនាគតនោះ គឺពួកក្រុមខ្មែរអាយ៉ងយួនដែលធ្លាប់ធ្វើជាខ្ញុំកញ្ជះយួនជាង ១០ ឆ្នាំ ក្រោយឆ្នាំ ១៩៧៩ ហើយដែលធ្លាប់ធ្វើជាខ្មែរក្រហមពីអតីតកាលឯណោះទេ...។



**បរិយាយខ្លងនេះ**

# មិនមែនជាការអភិវឌ្ឍន៍ទេ គឺជាសំណងខ្លែបំផ្លិចបំផ្លាញ

ដោយ អ.បុរីតន្រ្ត

ក្រោមការសហការដ៏សែនស្និទ្ធស្នាល និងការជួយជ្រោមជ្រែងយ៉ាងអស់ពីចិត្តពីថ្លើមរបស់ខ្មែរក្បត់ជាតិ លក់ក្បាលឱ្យយួនមួយក្រុម ប្រទេសកម្ពុជាត្រូវបានយួនចូលមកលុកលុយឈ្លានពានក្នុងដែនអធិបតេយ្យភាព ឯករាជ្យភាព និងបូរណភាពទឹកដីនៅថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ ក្រោមរូបភាពមករំដោះប្រជារាស្ត្រខ្មែរពីរបបប៉ុលពត អៀង សារី ។ ដើម្បីអំណាចតែមួយគត់ខ្មែរក្បត់ជាតិ ក្បត់ប្រជារាស្ត្រមួយក្រុមនោះសុខចិត្តយល់ព្រមឱ្យយួនដាក់អាណានិគមលើប្រទេសកម្ពុជាដោយគ្មានលក្ខខណ្ឌ ។

ក្នុងឋានៈជាប្រទេសរស់ក្រោមអាណានិគមបរទេសយួន ក្នុងឋានៈជាអ្នកដឹកនាំប្រទេសបែបអាយ៉ង របស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ហៅរដ្ឋកម្ពុជា ហៅគណបក្សប្រជាជនកម្ពុជា គ្មានបានធ្វើអ្វីទាល់តែសោះ សំរាប់ជាផលប្រយោជន៍ជាតិ និងប្រជារាស្ត្រខ្មែរឡើយ ។ ហើយផ្ទុយមកវិញរដ្ឋាភិបាលនេះបានខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់តាមគ្រប់រូបភាព គ្រប់មធ្យោបាយ និងបានផ្តល់ឱកាសយ៉ាងសំបូរបែបដល់យួនដើម្បីជួយជំរុញឱ្យនយោបាយលេបទឹកដីខ្មែររបស់យួនបានទទួលនូវជោគជ័យ ។

ក្រោយព្រឹត្តិការណ៍ឆ្នាំ ១៩៧៩ ក្នុងស្ថានភាពដែលប្រទេសកម្ពុជា ត្រូវបានរំដោះឱ្យរួចផុតពីរបបស្រេកឃ្លានប៉ុលពត អៀង សារី ក្នុងស្ថានភាពមួយដែលប្រទេសកម្ពុជាត្រូវបានបំផ្លាញស្ទើរគ្មានសល់នូវគ្រប់ផ្នែកគ្រប់វិស័យនៅទូទាំងប្រទេស គួរណាស់តែមេដឹកនាំរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលជាអាយ៉ងយួននេះប្រើប្រាស់ពេលវេលាដ៏ប្រពៃ និងឱកាសដ៏កំរមាននេះ (ពេលវេលាជាង១០ ឆ្នាំ ) ខិតខំខ្នះខ្នែងផុតដៃផុតជើងកែច្នៃទ្រព្យសម្បត្តិផ្សេងៗ និងធនធានគ្រប់ប្រភេទ ពិសេសធនធានធម្មជាតិ ដែលនៅសេសសល់មន្តិចបន្តួចពីរបបប៉ុលពត អៀងសារី ដើម្បីស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ ។ តែផ្ទុយមកវិញ តើរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាអាយ៉ងយួនមួយនេះ បានធ្វើអ្វីខ្លះដែលមានខ្លឹមសារថា បានអភិវឌ្ឍន៍ប្រទេសជាតិនោះ ?

ស្ថិតក្នុងពេលវេលាជាង ១០ ឆ្នាំ ក្រោមការដឹកនាំនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា (គណបក្សប្រជាជនកម្ពុជា ) រដ្ឋាភិបាលនេះមិនត្រឹមតែមិនបានកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ដែលត្រូវខ្ទេចខ្ទាំដោយសាររបប ៣ ឆ្នាំ ប៉ុណ្ណោះទេ ប៉ុន្តែរដ្ឋាភិបាលនេះបានសហការណ៍ជាមួយយួនបំផ្លាញទ្រព្យសម្បត្តិជាតិខ្មែរគ្រប់ប្រភេទ និងជាពិសេសថែមទាំងបានឱ្យយួនរាំងស្ទះវិស័យផ្សេងៗទៀតនៅកម្ពុជាមិនឱ្យដំណើរការទៀតផង ។ និយាយឱ្យខ្លី គឺរដ្ឋាភិបាលក្បត់ជាតិអាយ៉ងយួនមួយក្រុមនេះ បានចូលដៃចូលជើងសហការគ្នាជាមួយចៅហ្វាយនាយយួនរបស់ខ្លួនបន្តនយោបាយបំផ្លិចបំផ្លាញកម្ពុជាបន្តពីសម័យប៉ុលពត អៀងសារី យ៉ាងចាស់ដៃ ។

ផ្តើមចេញពីខ្លឹមសារ និងរូបភាពបែបនេះ ប្រទេសកម្ពុជាបានបណ្តោយឱ្យពេលវេលា និងឱកាសដ៏ប្រសើរក្នុងការអភិវឌ្ឍន៍ និងកសាងជាតិកន្លងហួសអស់រយៈពេលជាង ១០ ឆ្នាំ យ៉ាងក្រៀមក្រោះ និងសែនឈឺចាប់ជា

ទីបំផុត ។ តើការបំផ្លាញពេលវេលាក្នុងការកសាងជាតិអស់រយៈពេលជាង ១០ ឆ្នាំកន្លងមកនេះ គឺជាស្នាដៃរបស់អ្នកណា ? មិនគឺដោយសាររដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបច្ចុប្បន្នជាគណបក្សប្រជាជនកម្ពុជា ហើយដែលកំពុងកាន់តំណែងជានាយករដ្ឋមន្ត្រី ?

រំលឹកដល់អតីតកាល ប្រជារាស្ត្រខ្មែរយើងនៅមានការឈឺចាប់ខ្លោចផ្សារនៅឡើយទេ គឺរាស្ត្រយើងឈឺចាប់យ៉ាងក្រៃលែង នៅពេលដែលឃើញមេដឹកនាំរដ្ឋាភិបាលខ្មែរអាយ៉ងយួនបានបណ្តោយឱ្យយួនដឹក មាសពេជ្រ កេរ្តិ៍តំណែលជាតិខ្មែរ ព្រៃឈើ មច្ឆាជាតិខ្មែរ និងទ្រព្យសម្បត្តិផលធានសព្វបែបយ៉ាងរបស់ខ្មែរទៅប្រទេសវា ។ យើងនៅចាំមិនភ្លេចទេ នៅពេលដែលរដ្ឋាភិបាលអាយ៉ងយួនអនុញ្ញាតិឱ្យយួនបំផ្លាញឯកសារជាតិខ្មែរ បំផ្លាញអនាគតកូនខ្មែរ បង្ខាំងកូនខ្មែរមិនឱ្យទៅទទួលការសិក្សានៅប្រទេសជឿនលឿន និងជាពិសេសបង្ខំឱ្យកូនខ្មែររៀនភាសាយួន និងភាសារុស្ស៊ីជាដើម ។ល។

ស្ថិតនៅក្នុងស្ថានភាពបែបនេះ រយៈពេលជាង ១០ ឆ្នាំ តើប្រទេសខ្មែរទទួលការខាតបង់ប៉ុណ្ណា ? ក្រៅពីមាសពេជ្រ ទ្រព្យសម្បត្តិ កេរ្តិ៍តំណែលជាតិ ឯកសារជាតិ ព្រៃឈើ និងមច្ឆាជាតិ...ខ្មែរនៅទទួលការបាត់បង់ដ៏សែនធំធេងនូវទំនាក់ទំនងដ៏មានសារៈប្រយោជន៍ជាមួយអន្តរជាតិ ផ្នែកនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម ការបរទេស...។ ពិសេសខ្មែរនៅទទួលការបាត់បង់ទឹកដីរាប់សិបគីឡូម៉ែត្រ រួមទាំងជីវិតប្រជារាស្ត្ររាប់សែននាក់ និងបានបន្សល់ទុកនូវជនពិការ ស្ត្រីមេម៉ាយ កុមារកំព្រាយ៉ាងសន្ធឹកសន្ធាប់ដោយសារនយោបាយរបស់យួនក្នុងការប្រល័យពូជសាសន៍ខ្មែរ តាមរយៈផែនការ "ក ៥" និងការចាប់យុវជនខ្មែរឱ្យទៅស្លាប់ខ្លួនក្នុងសង្គ្រាមជាដើម ។

ដើម្បីបិទភ្នែក និងលុបលាងកំហុសឆ្គងក្នុងការដឹកនាំប្រទេសពីអតីតកាល គណបក្សប្រជាជនដែលមុននេះមានឈ្មោះថារដ្ឋកម្ពុជា និងសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលធ្លាប់ធ្វើខ្ញុំកញ្ជះយួនជាង ១០ ឆ្នាំ បានខិតខំដើរឃោសនាបោកប្រាស់ប្រជារាស្ត្រថា គណបក្សខ្លួនបានធ្វើការអភិវឌ្ឍន៍ប្រទេសជាតិច្រើនជាងគេបំផុត ។ ដូចជាសាលារៀន មន្ទីរពេទ្យ ប្រឡាយ និងទំនប់ទឹក ផ្លូវថ្នល់ សួនច្បារ...សរុបរាប់រយកន្លែង ។ ទាយទៅមើលថាតើប្រជារាស្ត្រលោកល្ងង់រហូតដល់ទៅជឿថា សកម្មភាពនេះ គឺជាចេតនាពិតប្រាកដរបស់គណបក្សប្រជាជនកម្ពុជាក្នុងការអភិវឌ្ឍន៍ជាតិ និងដើម្បីធ្វើការកែទំរង់ជីវភាពរស់នៅរបស់រាស្ត្រឱ្យប្រសើរឡើងឬ ?

សូមមេដឹកនាំគណបក្សកុំមុយនីស្តកុំច្រលំឱ្យសោះ ប្រជារាស្ត្រលោកឈប់ល្ងង់យូរហើយ ហើយប្រជារាស្ត្រលោកយល់ច្បាស់ណាស់ថា សមិទ្ធិផលទាំងអម្បាលម៉ាណដែលគណបក្សកុំមុយនីស្តបង្កើតឡើង វាពុំមែនជាការអភិវឌ្ឍន៍អីទេ ។ តែតាមការពិតសមិទ្ធិផល និងអ្វីៗផ្សេងទៀតដែលគណបក្សកុំមុយនីស្តបានធ្វើកន្លងមកវាគ្រាន់តែជាការសងថ្លៃការបំផ្លិចបំផ្លាញពីអតីតកាលប៉ុណ្ណោះ ។

ព្រួតដៃគ្នាជាមួយយួនបំផ្លាញប្រទេសកម្ពុជាជាង ១០ ឆ្នាំ កន្លងមកហើយ ទើបតែភ្ញាក់ខ្លួនពីម្សិលមិញហើយខិតខំប្រឹងប្រែងលួចលុយជាតិ និងប្រជារាស្ត្រយ៉ាងសន្ធឹកសន្ធាប់ ដើម្បីយកមកបង្កើតសមិទ្ធិផលផ្សេងៗបានបន្តិចបន្តួចប៉ុណ្ណឹង ស្មានតែអាចទូទាត់កាត់សងថ្លៃការបំផ្លិចបំផ្លាញពីអតីតកាលបានឬ...ខិតខំធ្វើទៅព្រោះតាំងពីឆ្នាំ ១៩៧៩ រហូតដល់ឆ្នាំ ១៩៩១ គណបក្សកុំមុយនីស្តបានបំផ្លាញប្រជារាស្ត្រ និងប្រទេសជាតិច្រើនណាស់ ។

ទស្សនៈនិស្សិត :

# ប្រជាប្រិយភាពដែលបានមកពីអំពើចោរកម្ម

ដោយសារភាពផ្តាច់ការក្នុងការដឹកនាំប្រទេសជាតិរបស់គណបក្សប្រជាជន ដែលមានប្រភពមកពីរដ្ឋកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាអាយ៉ងយួនសុទ្ធសាធ ។ ដោយសារគណបក្សកុំមុយនីស្តនេះព្រងើយកន្តើយជាមួយប្រជារាស្ត្រ ហើយរវល់ជាប់ដែបំរើចៅហ្វាយនាយយួនរយៈពេលជាង ១០ ឆ្នាំភ្លេចគិតពីការកសាង និងអភិវឌ្ឍន៍ប្រទេស ។ ដោយសារគណបក្សកុំមុយនីស្តនេះបានប្រព្រឹត្តអំពើលក់ជាតិ និងពុករលួយយ៉ាងអស់សាច់ ពិសេសបានធ្វើឱ្យកម្ពុជាបាត់បង់ឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដី... បានធ្វើឱ្យគណបក្សនេះទទួលបានប្រជាប្រិយភាពពីប្រជារាស្ត្រតិចជាងគណបក្សប្រឆាំងដ៏ធំមួយ គឺគណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិចក្នុងការបោះឆ្នោតកាលពីឆ្នាំ ១៩៩៣ កន្លងទៅនេះ ។

រីឯគណបក្សហ្វ៊ុនស៊ិនប៉ិច ការដែលខ្លួនទទួលបានប្រជាប្រិយភាពពីប្រជារាស្ត្រក្នុងចំណាត់ថ្នាក់លេខមួយក៏ដោយសារគណបក្សនេះបានសន្យាថាខ្លួន នឹងខិតខំលុបបំបាត់នូវអ្វីៗទាំងអស់ដែលគណបក្សប្រជាជនបានធ្វើខុសឆ្គងក្នុងការដឹកនាំជាតិក្នុងរយៈកាលកន្លងមក ។ ក្រោយពីបានកាន់អំណាចដឹកនាំប្រទេសមួយរយៈ ដោយសារ : អំណាច វិទ្យា លាភ ដុល្លា និងសំភារៈទំនើបៗ បានធ្វើឱ្យគណបក្សនេះពុលឈ្លក់វង្វេងឡប់ទាំងមេទាំងកូនអស់មួយពូជ ភ្លេចគិតគូរពាក្យសន្យា ។ ម្ល៉ោះហើយប្រជាប្រិយភាពដែលគណបក្សនេះបានមកត្រូវរលាយបាត់ទៅវិញយ៉ាងប្រញាប់ប្រញាលបំផុត ក្នុងកំរិតមួយកែលែងឡើង ។

បច្ចុប្បន្ននេះស្ថិតក្នុងសភាពមានកំហុសឆ្គងធ្ងន់ធ្ងរដូចគ្នា ក្នុងនយោបាយដឹកនាំប្រទេសជាតិ នៅក្នុងរដ្ឋាភិបាលចម្រុះបង្រួបបង្រួមជាតិ គណបក្សធំៗទាំងពីរបានខិតខំប្រឹងប្រែងអស់ពីលទ្ធភាព ប្រើប្រាស់តាមគ្រប់រូបភាព គ្រប់មធ្យោបាយ ក្នុងបំណងស្តារឡើងវិញនូវប្រជាប្រិយភាពគណបក្សខ្លួនដែលត្រូវបានបាត់បង់ពីអតីតកាល និងបច្ចុប្បន្ន។ ហើយ គឺដើម្បីប្រជាប្រិយភាពនយោបាយសំរាប់គណបក្សខ្លួននីមួយៗនេះហើយ ដែលបានជំរុញឱ្យគណបក្សទាំងពីរនេះ ហ៊ានប្រព្រឹត្តសកម្មភាពគ្រប់យ៉ាងទោះបីជាសកម្មភាពនោះរំលោភអយុត្តិធម៌ សាហាវឃោរឃៅ រំលោភសិទ្ធិមនុស្ស និងចោរកម្មយ៉ាងណាក្តី ។

ហេតុនេះដើម្បីរក្សាការពារ និងលើកកំពស់នូវប្រជាប្រិយភាពរបស់ខ្លួន គណបក្សធំៗទាំងពីរដែលកំពុងដឹកនាំរដ្ឋាភិបាល ពិសេសគណបក្សប្រជាជនបានជ្រើសរើសយកមធ្យោបាយដ៏គួរឱ្យភ័យខ្លាចយកមកអនុវត្ត ។ ការកំទេចអ្នកនយោបាយប្រជាធិបតេយ្យ និយមការគោរពសិទ្ធិមនុស្សពីឆាកនយោបាយ ការប្រើប្រាស់អំពើហិង្សា និងការគំរាមកំហែងអាយុជីវិតអ្នកសារព័ត៌មានដែលបំរើឱ្យផលប្រយោជន៍ជាតិ និងប្រជារាស្ត្រ គឺជាអាទិភាពចំបង

របស់រដ្ឋាភិបាលសហនាយកនេះ ។ ជាភស្តុតាងអ្នកកាសែតត្រូវបានសំលាប់ និងចាប់ដាក់គុក អ្នកតំណាងរាស្ត្រ និងរដ្ឋមន្ត្រីមួយចំនួនត្រូវបានដកចេញពីតំណែង និងត្រូវនិរទេស ។

គណបក្សប្រឆាំងស្របច្បាប់ត្រូវទទួលការគំរាមកំហែងដោយអំពើហឹង្សា ការញុះញង់បំបែកបំបាក់ដោយគណបក្សកាន់អំណាច ។ ជានិច្ចកាលគណបក្សកាន់អំណាចតែងផ្តល់ភាពស្របច្បាប់ដល់ក្រុមគណបក្សដែលបានបំបែកខ្លួនចេញពីគណបក្សប្រឆាំង ហើយដែលបានគាំទ្រនយោបាយខ្លួន ។ ហេតុការណ៍នេះ បានធ្វើឱ្យមានភាពអាណាធិបតេយ្យពេញបន្ទុកក្នុងវិស័យនយោបាយ ។ ជាងនេះទៅទៀត គណបក្សកាន់អំណាចបានប្រើប្រាស់រដ្ឋអំណាច និងទឹកលុយរបស់ខ្លួនជួលជនដៃដល់ឱ្យប្រព្រឹត្តអំពើហិង្សា ពាលាអាវ៉ាសែ គំរាមកំហែងមិនឱ្យគណបក្សប្រឆាំងធ្វើសកម្មភាព ។ ជាភស្តុតាងគណបក្សជាតិខ្មែរ ដែលជាគណបក្សប្រឆាំងដ៏ធំមួយ នៅពេលទៅបើកទីស្នាក់ការរបស់ខ្លួននៅតាមបណ្តាខេត្តនានា ត្រូវបានកំលាំងរដ្ឋអំណាច និងជនដៃដល់ធ្វើការបាញ់ប្រហារ និងកាប់កំទេចផ្លាកគណបក្សនោះចោលយ៉ាងព្រៃផ្សៃ ។ ហើយសកម្មភាពនេះត្រូវបានសហនាយករដ្ឋមន្ត្រីគាំទ្រ និងលើកទឹកចិត្ត ។

ជាងនេះទៅទៀតគណបក្សកាន់អំណាច បានប្រើប្រាស់រដ្ឋអំណាចរបស់ខ្លួន សំឡុតគំរាមកំហែងបង្ខំឱ្យប្រជារាស្ត្រថតរូប ឬយករអត្តសញ្ញាណប័ណ្ណដើម្បីសរសេរពាក្យចូលជាសមាជិកភាពនៅក្នុងគណបក្សខ្លួន ហើយសកម្មភាពបង្ខំនេះ គណបក្សប្រជាជនកំពុងតែអនុវត្តនៅទូទាំងប្រទេសកម្ពុជា ។ មេត្រួសារនៅតាមបណ្តាខេត្តត្រូវបានរដ្ឋអំណាចមូលដ្ឋានគណបក្សប្រជាជន បង្ខំឱ្យស្ម័គ្រចិត្តទទួលលើកផ្លាកសញ្ញាគណបក្សនេះនៅមុខគេហដ្ឋានរបស់ខ្លួន ។ ផ្ទុយមកវិញ គណបក្សនេះបានបញ្ជាទៅរដ្ឋអំណាចមូលដ្ឋានគំរាមប្រជាជនណាដែលបានអនុញ្ញាតឱ្យគណបក្សប្រឆាំងបើកទីស្នាក់ការនៅក្នុងគេហដ្ឋានរបស់ខ្លួនទៅវិញ ។

ការប្រព្រឹត្តអំពើពុករលួយ ដើម្បីទិញយកការគាំទ្រ និងប្រជាប្រិយភាពត្រូវបានគណបក្សកាន់អំណាចទាំងពីរអនុវត្តពេញទំហឹង និងដោយចំហរ ។ ទឹកប្រាក់រាប់ពាន់លាន ត្រូវបានគណបក្សទាំងពីរ ពិសេសគណបក្សប្រជាជនយកទៅប្រើប្រាស់ដើម្បីផ្តល់ឱ្យសាស្ត្រចារ្យ សិស្ស និស្សិត បញ្ញវ័ន្ត និងប្រជារាស្ត្រដែលអាចផ្តល់ផលប្រយោជន៍ដល់គេ ។ ទឹកប្រាក់ ៣០ ០០០ រៀល ត្រូវបានផ្តល់ជូនដល់ប្រជារាស្ត្រណាដែលបានក្លាយទៅជាសមាជិកភាពគណបក្សប្រជាជន ។

ការសេពគប់ជាមួយឈ្មួញទុច្ចរិតរកស៊ីខុសច្បាប់ ការលួចលុយជាតិនិងប្រជារាស្ត្រ ការបំផ្លាញផលិតផលផ្សេងៗរបស់ជាតិ ពិសេសព្រៃឈើ ត្រូវបានគណបក្សកាន់អំណាចប្រព្រឹត្តដោយគ្មានញញើតដៃ និងគ្មានគោរពច្បាប់ទំលាប់ ។ ហើយសកម្មភាពនេះបានផ្តល់មកឱ្យប្រជារាស្ត្រវិញនូវសាលារៀន ផ្លូវថ្នល់ មន្ទីរពេទ្យ ប្រឡាយទឹកដ៏សែនតិចតួចបំផុត ។ ថវិការជាតិរាប់រយ រាប់ពាន់លានរៀលត្រូវបានគណបក្សកាន់អំណាចយកទៅប្រើប្រាស់ក្នុងផលប្រយោជន៍ផ្ទាល់ខ្លួនក្នុងអំឡុងពេលចុះឃោសនា ។ ការយកលុយម្តងពី៥ ទៅ ១០លាន រៀល ដើម្បីធ្វើជាអំណោយក្នុងពិធីចុះទៅសម្ពោធ ទៅធ្វើជាអធិបតី និងការចុះទៅសាកសួរសុខទុក្ខប្រជារាស្ត្រ បានធ្វើឱ្យថវិការជាតិបាត់បង់ដោយពុំមានសមិទ្ធិផលជាតិអ្វីបន្តិចបន្តួច ដែលបានមកវិញពីការចំណាយលុយនោះក្រៅពីប្រជាប្រិយភាពសំរាប់អ្នកចែកអំណោយនោះឡើយ ។

ស្ថិតក្នុងស្ថានភាពគណបក្សប្រឆាំង អ្នកសារពត៌មានប្រឆាំងដែលហ៊ានចុះផ្សាយ ហ៊ាននិយាយការពិត ហ៊ានរិះគន់ អ្នកមានគំនិតយោបល់ប្រឆាំងត្រូវបានទទួលការគំរាមកំហែង និងការប្រើប្រាស់អំពើហឹង្សាពីគណបក្សកាន់អំណាច ស្ថិតក្នុងទំងន់នៃអំពើពុករលួយរបស់គណបក្សកាន់អំណាច បានធ្វើឱ្យមជ្ឈដ្ឋានទាំងឡាយមើលទៅឃើញថា អ្វីៗទាំងអស់នៅកម្ពុជា គឺជារបស់គណបក្សកាន់អំណាច ហើយអ្វីដែលល្អបំផុត គណបក្សដែលមានប្រជាប្រិយភាពបំផុត គឺគណបក្សកាន់អំណាច ។ ដោយសារអ្វីៗដែលមិនមែនជារបស់គណបក្សកាន់អំណាចត្រូវបានប្រឆាំងបដិសេធ និងទទួលការគំរាមកំហែង ហេតុនេះហើយទើបអ្វីៗដែលមិនមែនជារបស់គណបក្សកាន់អំណាចមិនអាចកើតឡើងបាន និងមិនអាចទទួលនូវប្រជាប្រិយភាពក្នុងភាពចំហរបានឡើយ ។

ដូចនេះឃើញថា ដើម្បីទទួលបាននូវប្រជាប្រិយភាពពីប្រជារាស្ត្រក្នុងការគាំទ្រគណបក្សខ្លួន គណបក្សកាន់អំណាចបាន ប្រព្រឹត្តអំពើថោកទាបច្រើនប្រការណាស់ ។ តែថា ការពិតនៅតែជាការពិត ហើយបើយើងធ្វើការពិនិត្យឱ្យ បានដិតដល់ទៅទើបមើលឃើញថា ប្រជាប្រិយភាពនោះ គឺជាប្រជាប្រិយភាពដែលមិនបិតថេរ គឺជាប្រជាប្រិយភាពដែលមិនមែនចេញមកពីបេះដូងបរិសុទ្ធរបស់ប្រជារាស្ត្រទេ ។ ព្រោះថា ប្រជាប្រិយភាពរបស់គណបក្សកាន់អំណាច ពិសេសគណបក្សកុម្មុយនិស្តបានមកពីអំពើថោកទាបបំផុត ។

ដោយកញ្ញា ធីតា



ទស្សនៈនិស្សិត :

# នយោបាយលាបពណ៌របស់អ្នកនយោបាយ

*ដោយ ទិសេស_គតិយុត្តិ*

តាំងពីដើមរៀងរហូតមកប្រវត្តិសាស្ត្រកម្ពុជាបានបង្ហាញយ៉ាងច្បាស់នូវមហន្តរាយ និងភាពវេទនាខ្លោចផ្សារបស់ប្រជាជាតិ និងមាតុភូមិខ្មែរនៅក្នុងអណ្តាតភ្លើងសង្គ្រាមផ្ទៃក្នុងដែលបង្កឡើងដោយសារអ្នកនយោបាយ។ នៅគ្រប់សម័យកាលកម្ពុជាតែងតែមានអ្នកដឹកនាំ បែងចែកជាច្រើនបក្សច្រើនក្រុមផ្សេងៗគ្នាហើយមានទស្សនៈខុសៗគ្នា និងធ្វើការប្រឆាំងប្រទេសគ្នាជានិច្ច។ អ្នកដឹកនាំដែលឡើងកាន់អំណាចនៅពេលទទួលបានជ័យជំនះតែងធ្វើការចោទប្រកាន់និងវាយបន្ទាបបន្ថោកនូវគំនិតការងារដឹកនាំរបស់អ្នកនយោបាយជំនាន់មុនៗគ្នាជារៀងរហូតមក ។

កមិនខុសគ្នាប៉ុន្មានដែរ ក្រោយពេលបោះឆ្នោតជាសកលនៅកម្ពុជានាឆ្នាំ១៩៩៣មក កម្ពុជាបានបង្កើតរាជរដ្ឋាភិបាលចំរុះមួយក្នុងចំណោមគណបក្សដែលបានឈ្នះឆ្នោត ។ ប៉ុន្តែជាអកុសលរហូតមកដល់ពេលនេះទៅ

ហើយ កម្ពុជានៅតែពុំទាន់សុខស្ងប់ខាងផ្នែកនយោបាយនៅឡើយ ព្រោះនៅមានអ្នកនយោបាយខ្លះខកបំណង និងមានគណបក្សមួយចំនួនធំពុំបានជាប់ឆ្នោត ។ បន្ថែមលើនោះទៀតគ្រោះកាចកាន់តែអាក្រក់គឺកម្ពុជានៅតែឆ្អាបក្លិនឈាម ឈ្ងៀមក្លិនរំសេវ ។ ភ្លើងសង្គ្រាមដែលមានចំណាស់ជាងពីរទសវត្សនៅកម្ពុជាពុំទាន់ផុតរលត់ទេ ។ ដំណើរការសន្តិភាពជាហូរហែកន្លងមកគឺពុំទទួលបានលទ្ធផលជាវិជ្ជមានឡើយ ទោះបីជាមានព្រះរាជបេសកកម្មដ៏ខ្នះខ្នែងរបស់ព្រះមហាក្សត្រ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រមទាំងគ្រប់ភាគីពាក់ព័ន្ធក្តី ។

ការមិនទុកចិត្តគ្នា ការបែងជើងគ្នា ការបញ្ជោះបន្សោកអុជអាលគ្នា ធ្វើឬកឫញមាត់បត់ជុំដៃ ពោលគឺនយោបាយលាបពណ៌គ្នាគឺជាចរិតនយោបាយពីកំណើតរបស់អ្នកនយោបាយខ្មែរស្ទើរគ្រប់រូប គ្រប់ជំនាន់ទៅហើយ។ អ្នកនយោបាយមួយចំនួនមានមាយាទជាអ្នកចូលចិត្តបង្កជំលោះ រឿងរ៉ាវតូចតាចសោះក៏ផ្តួចផ្តើមពង្រីកង វៀសវ៉ាសរកល្បិចជាលេសនេះ លេសនោះដើម្បីឈ្លោះទាស់ទែង និងដើម្បីបានបន្តនូវអំពើវិនាសកម្មដោយគ្មានមនុស្សធម៌មកលើប្រជាជាតិឯង ។ អ្នកនយោបាយមួយចំនួនចូលចិត្តតែដើរហែកហួរពីរឿងខ្មែរហើយបកប្រែឱ្យបរទេសស្តាប់ បន្ថែមអព្ចេះ បន្ថយអព្ចុះតាមតែចិត្តនឹកឃើញ វាមិនខុសអ្វីពីមនុស្សឆ្កួតហែកទ្រូងខ្លួនឯងឱ្យក្អែកចឹកនោះទេ ។ កន្លងមកប្រវត្តិសាស្ត្រក៏បានបង្ហាញនូវសោកនាដកម្មនានាជាច្រើនដែលកើតឡើងដោយសារការលាបពណ៌នេះ។ យើងឃើញថាដោយសារតែគេចង់បំផ្លាញភាគីម្ខាងទៀត គេអាចប្រើនយោបាយដ៏គ្រោះថ្នាក់ និងដ៏ថោកទាបនេះដើម្បីចាប់អ្នកនយោបាយប្រឆាំងដាក់គុកងងឹត ឬប្រហារជីវិតយ៉ាងអមនុស្សធម៌ទៀតផង ។ ហើយដើម្បីជាលេសបិទបាំងអំពើថោកទាបនេះគេអាចប្រកាសថា អ្នកដែលរងគ្រោះនោះគឺជាជនក្បត់ជាតិ ។

នយោបាយបន្តុំ លាបពណ៌ និងចោទប្រកាន់គ្នានេះវាមានលក្ខណៈគ្រោះថ្នាក់បំផុតនៅពេលដែលបុគ្គលអគតិមើលឃើញតែប្រយោជន៍ផ្ទាល់ខ្លួន គំនុំផ្ទាល់ខ្លួនហើយរិះរក និងយកមធ្យោបាយរួមទៅសងសឹកទៅលើបុគ្គលក្រុម ឬបក្សពួកផ្សេងមួយទៀតដោយពុំគិតប្រយោជន៍ជាតិ និងទុក្ខវេទនារបស់រាស្ត្រ ។ វាជាការពុំត្រឹមត្រូវទាល់តែសោះ និងរឹតតែធ្ងន់ធ្ងរណាស់ទៅទៀតនៅពេលដែលមានអ្នកនយោបាយខ្មែរម្នាក់_មួយក្រុមហារមាត់ជេរប្រមាថដល់បុគ្គល ឬក្រុមអ្នកនយោបាយខ្មែរផ្សេងមួយទៀតថា "អាក្បត់ជាតិ ឬពួកអាក្បត់ជាតិ" ។ ក្នុងនាមជាអ្នកដឹកនាំជាតិ អ្នកនយោបាយគួរតែប្រមើលមើលឱ្យឃើញច្បាស់ថាយ៉ាងធ្ងន់ធ្ងរបំផុតបុគ្គលម្នាក់ ឬខ្មែរមួយក្រុមទៀតនោះជាអ្នកដែលមិនចេះស្រឡាញ់ជាតិ ពុំចេះអាណិតជាតិ ហើយត្រឹមតែចង់បានអំណាចដោយអគតិ ប៉ុណ្ណោះវាជាការគ្រប់គ្រាន់ណាស់ទៅហើយ ។ វាជាការគ្រោះថ្នាក់មួយដែរគឺនៅពេលដែលអ្នកនយោបាយមានតួនាទីសំខាន់ក្នុងការដឹកនាំជាតិ មានអំណាចឥទ្ធិពលហើយធ្វើអ្វីមួយ ឬសំរេចកិច្ចការណាមួយដោយពុំបានតាមដានពិចារណាឱ្យសុក្រិត ហើយអនុវត្តទៅតាមការញុះញង់របស់អាម៉ុអាចោងនោះ ។ ទង្វើរបស់អ្នក សេចក្តីសំរេចដោយមោហ៍ជាំងរបស់អ្នកវានឹងនាំគ្រោះមហន្តរាយដល់អ្នកត្រឹមត្រូវស្លូតត្រង់ នោះវិប្បដិសារីនឹងជេរស្តីអ្នករហូតដល់ថ្ងៃស្លាប់មិនខាន ។ ជាតិខ្មែរយើងនៅតែប្រឈមមុខនឹងគ្រោះមហន្តរាយធំជាងរាប បើកាលណាមានខ្មែរច្រើនក្រុមនៅតែស្រែកជេរគ្នាទៅវិញទៅមកថា "អាក្បត់ជាតិ" ហើយតាមរករឿងឈ្លោះទាស់ទែងកាលណាគេមិនស្របតាមខ្លួន ។

មេរៀនប្រវត្តិសាស្ត្រដ៏ជូរចត់ជាច្រើនបានបង្ហាញឱ្យយើងឃើញហើយពីគ្រោះមហន្តរាយរបស់ខ្មែរ ។ អ្នកដឹកនាំ អ្នកនយោបាយដែលប្រកាន់និន្នាការខុសៗគ្នា ប្រកាន់ទស្សនៈផ្សេងៗគ្នាតែងធ្វើការប្រមូលសរវ៉ាយ និងប្រឈម

មុខដាក់គ្នាជានិច្ចកាល ។ អ្នកនយោបាយភាគច្រើនៗតែមានទស្សនៈអញនិយម មានតែអញ មានតែក្រុមអញទើបត្រឹមត្រូវជាងគេ ល្អជាងគេ ។ គេមិនដែលឃើញពីចំនុចខ្សោយរបស់ខ្លួន និងមិនដែលមើលឃើញពីចំនុចខ្លាំងភាពត្រឹមត្រូវរបស់អ្នកដទៃ ។ កាលណាមាននរណាម្នាក់ ឬក្រុមណាមួយចង់កែលំអគេ គេចាប់ផ្តើមមួម៉ៅក្តៅក្រហាយ និងគំរាមកំហែងបំបិតមាត់គេភ្លាម ។ ការស្តាប់ ការយល់ឃើញថាត្រឹមត្រូវតែពួកខ្លួន និងខ្លួនឯងវាបានធ្វើឱ្យទាំងអ្នកនយោបាយ និងអ្នកដឹកនាំមួយចំនួនបានអនុវត្តការងារដោយភ័ន្តច្រឡំបង្កគ្រោះមហន្តរាយទាំងផ្ទាល់ និងប្រយោលដល់អ្នកស្លូតត្រង់មានគំនិតអព្យាក្រឹត មានគំនិតជាតិនិយមស្នេហាប្រជារាស្ត្រ ទឹកដី និងពូជពង្សខ្មែរ ។ ជាឧទាហរណ៍កន្លងមកក៏មានប្រភេទអ្នកនយោបាយដែលចូលចិត្តសេពគប់ល្បែងខាងលើតែងលាបពណ៌តែពីសតែពាសទាំងមិនមានមូលដ្ឋានពិតប្រាកដធ្វើការចោទប្រកាន់លាបពណ៌ទាំងវើរវាយផ្តេសផ្តាសថាម្តងសមាគមនិស្សិតខ្មែរជារបស់គណបក្សនេះ ម្តងជារបស់គណបក្សនោះមិនឈប់មិនឈរតាមតែចិត្តនឹកឃើញ ។ ប៉ុន្តែធាតុពិតវានៅតែពិតសមាគមនិស្សិតខ្មែរដែលជាសមាគមមួយមានគោលការណ៍ត្រឹមត្រូវ ប្រកាន់ជំហរឯករាជ្យ អព្យាក្រឹត និងដាច់ខាតមិនមាននិន្នាការនយោបាយចំពោះគណបក្សណាមួយឡើយ ។

ដូច្នេះវាល្មមគ្រប់គ្រាន់ណាស់ហើយវាល្មមឆ្អែតឆ្អន់ហើយអស់លោកអ្នកនយោបាយខ្មែរដែលចូលចិត្តតែលេងល្បែងលាបពណ៌ចោទប្រកាន់បំបែកបំបាក់សាមគ្គីធម៌រវាងខ្មែរ និងខ្មែរទាំងកន្លងមកនោះ ។ បើចង់ឱ្យជាតិយើងអភិវឌ្ឍន៍ចំរើនជឿនលឿនចាកផុតពីការមើលងាយមើលថោករបស់ពួកបរទេសមកលើកម្ពុជាជាទីស្នេហានៃយើងគួរណាស់អស់លោកអ្នក ដែលធ្លាប់តែលាបពណ៌ និងកំពុងតែលាបពណ៌ដល់អ្នកដទៃ សូមមេត្តាបញ្ឈប់សកម្មភាពអគតិរបស់លោកអ្នកជាបន្ទាន់ ។ ចំពោះអ្នកដែលធ្លាប់តែបំផ្លាញតាមគ្រប់រូបភាពក៏ត្រូវតែបញ្ឈប់អំពើថោកទាបរបស់ខ្លួន ព្រមទាំងឈប់បៀមឈាមព្រួសដាក់អ្នកដទៃទៅ ។ សូមអ្នកនយោបាយខ្មែរទាំងអស់ញញឹមរាក់ទាក់រកគ្នា រួបរួមសាមគ្គីគ្នាទៅទើបជាតិយើងបានសុខរាស្ត្រផុតទុក្ខអំពល់ ។ សូមអ្នកនយោបាយខ្មែរគ្រប់រូបដែលចូលចិត្តប្រើនយោបាយលាបពណ៌នេះបោះបង់វាចោលទៅព្រោះវាជាប្រភេទគ្រោះថ្នាក់មួយដែលធ្វើឱ្យខ្មែរយើងអន្តរាយងើបមុខមិនរួច ។



វេទិកាសេរី

# ឧត្តមគតិអ្នកសារព័ត៌មានខ្មែរបច្ចុប្បន្ន

កម្ពុជាយើងទើបតែមានការរួបរួមសាមគ្គីគ្នា ហើយបោះជំហានទៅរករបបមួយដែលមានឈ្មោះថារបបប្រជាធិបតេយ្យ ។ ជាការពិតណាស់សំរាប់ប្រទេសមួយដែលប្រកាន់យកនូវរបបប្រជាធិបតេយ្យនេះត្រូវតែបើកទូលាយនូវការបញ្ចេញឆន្ទៈ មតិយោបល់របស់រាស្ត្រជាទូទៅ ដើម្បីជួយជាការកែលំអដល់ទង្វើរបស់រាជរដ្ឋាភិបាល ហើយកំរែកំរង់ផ្លូវឱ្យឈានទៅរកអ្វីដែលល្អប្រសើរ អ្វីជាបំណងប្រាថ្នារបស់រាស្ត្រទូទៅនោះ ។

ការកើតមានឡើងនូវបណ្តាញផ្សាយព័ត៌មានតាមកាសែត ដែលរហូតមកដល់នេះរាប់ទៅគឺមានជិតដល់ ៥០ ទៅហើយ ។ តើអស់លោកជានិពន្ធនាយក ជាម្ចាស់ប្លង់ការផ្សាយនៃសារព័ត៌មានទាំងនោះមានទស្សនៈ និងឧត្តមគតិយ៉ាងណាចំពោះជាតិ ? បើតាមការពិនិត្យទៅឃើញថា ប្រហែលជាមិនសូវមានទស្សនៈជាតិដោយសុឆន្ទៈទេ ។ កាសែតខ្លះសរសេរការពារផលប្រយោជន៍ឈ្មួញទុច្ចរិត ការពារអ្នកមានអំណាចមានលុយ កាសែតខ្លះទៀតកើតឡើងសំរាប់ធ្វើអាជីវកម្មក្នុងផ្លូវមិនសមស្របដើម្បីតែបំរើប្រយោជន៍ផ្ទាល់ខ្លួន គឺចំចោងដំណឹងកៀបសុំលុយតែម្តង ។ ឯកាសែតមួយចំនួនទៀតកាន់តែប្រាសចាកនូវលក្ខណៈពិសេស និងប្រពៃណីល្អរបស់ជាតិ ពោលគឺគេសរសេរឡើងដោយមិនគិតពីតំលៃនៃជាតិ និងភាពថ្លៃថ្នូររបស់ស្ត្រីឡើយ ។

តើអស់លោកដែលបង្កើតកាសែតទាំងនោះ មានដែលគិតពីគោលការណ៍តាំងខ្លួនជាជនជាតិខ្មែរ ជាអ្នកថែរក្សា និងការពារនូវវប្បធម៌ ប្រពៃណី ទំនៀមទំលាប់ជាតិខ្មែរទេ? បើអស់លោកមួយចំនួនធំសរសេរកាសែតដូចសព្វថ្ងៃនេះ មានដែលបានគិតពីក្រមសីលធម៌វិជ្ជាជីវៈជាអ្នកកាសែតដែរឬទេ ? ជាការពិតណាស់អ្នកកាសែតជាមនុស្សដែលមានតំលៃណាស់នៅក្នុងសង្គម ហើយបណ្តាញសារព័ត៌មានត្រូវតែខ្លាំងសក្តិសមជាអំណាចទី៤ ។ ប៉ុន្តែតើអ្នកកាសែតមួយភាគធំនាបច្ចុប្បន្ននេះអាចចាត់ទុកជាមនុស្សមានតំលៃដែរឬទេ ? ចំឡែកតែមានរឿងហេតុខ្លះរ៉ាប់រួសពីការស្មាន រ៉ាប់រួសពីការពិត ជាពិសេសទាក់ទងរឿងមិនសមរម្យរបស់ស្ត្រីខ្មែរនៅក្នុងសង្គមបច្ចុប្បន្នអស់លោកគួរតែថ្លឹងថ្លែងដែរថាតើគួរចុះផ្សាយ ឬមិនចុះផ្សាយ ជាពិសេសការគូររូបអាសអាភាសតាមកាសែត ។ សកម្មភាពចុះផ្សាយរបស់អស់លោកគឺជាការវាយបន្ថោកតំលៃរបស់ស្ត្រីខ្មែរយើងយ៉ាងពេញទី ។ រាល់ការចុះផ្សាយអស់លោកគួរតែគិតពីសីលធម៌វិជ្ជាជីវៈ សីលធម៌ផ្ទាល់ និងសីលធម៌សង្គមជាតិយើងផង ។ សូមអស់លោកតាំងខ្លួនជាអ្នកទិតៀនដើម្បីការកែលំអ ទិតៀនដើម្បីលើកតំកើងវប្បធម៌ជាតិ មិនមែននិយាយទិតៀនតាមបែបជាន់ពន្លិចជាតិដូចសព្វថ្ងៃនេះទេ ។

រូបភាពអាសអាភាស រូបភាពសោកនាដកម្មរំពឹងជាបានចាក់ទម្លុះទៅដល់ដួងចិត្តនៃមនុស្សគ្រប់រូប ជាពិសេសគឺក្មេងៗ ដែលងាយនឹងទទួលយកហើយឆាប់ភ្លើតភ្លើន ។ កុំសូម្បីដល់ក្មេងដែលចេះអានអក្សរយល់ដឹងសេចក្តីបានសូម្បីតែក្មេងមិនទាន់ចេះអានក៏រងនូវឥទ្ធិពលអាក្រក់នេះដែរ ពេលដែលឃើញរូបភាពស្រើបស្រាល អាសអាភាសទាំងនោះ ។ ព្រោះថាមនុស្សយើងទាំងចាស់ទាំងក្មេងភាគច្រើនគឺងាយនឹងធ្លាក់ទៅក្នុងអំពើអនាចារនេះ

ណាស់ ។ លោកអ្នកគួរតែអាសូរដល់ក្មេងៗ ដែលនឹងក្លាយអ្នកបន្តវេនក្នុងការកសាងជាតិទាំងនេះផង ។ មិនយូរទេក្មេងៗមួយចំនួននឹងក្លាយទៅជាអ្នកបន្តវេនរបស់លោកអ្នក តើអស់លោកចង់ឱ្យក្មេងៗវាបន្តវេនទៅលើសកម្មភាពអាក្រក់ទាំងនោះឬ? ដោយសារតែរឿងផ្តេសផ្តាសទាំងនេះវាបើកទូលាយខ្លាំងពេក ទើបឥឡូវនេះក្មេងៗទាំងស្រីទាំងប្រុសបានក្លាយទៅជានំដែលធំហួសនាឡិកាំងពីពុំទាន់ជ្រុះពន្លៃពីក្បាលម្លេះ ។ ក្មេងៗទាំងស្រីទាំងប្រុសភ្លើតភ្លើនស្ទើរភ្លេចអ្វីទាំអស់របស់ខ្មែរ ភ្លេចចរិតជាតិកំណើតរបស់ខ្លួន ភ្លេចស្ទើរអស់ការសិក្សា នាំគ្នាក្រលៃវប្បធម៌ជាតិខ្មែរឱ្យលឿនហួសសម័យនុយក្លេអ៊ែរទៅទៀត ។

កាសែតមួយចំនួនមានកោះសន្តិភាព ទស្សនាវដ្តីប្រជាប្រិយជាដើម តែងតែចុះផ្សាយនូវអត្ថបទ និងរូបភាពអាសអាភាសជារៀងរាល់លេខ ។ ជួនកាលរូបភាពអាសអាភាសទាំងនោះ ផ្សាយនៅឯបរទេសតាមវប្បធម៌គេសោះ វាឆ្លងមកដល់ត្បូកូនខ្មែរថតផ្សាយឱ្យកូនខ្មែរមើលលេចលើលេចក្រោម ចំហរកៀនកោះហើយអួតកុហកទាំងស្រស់ៗថារូបថតសិល្បៈ ចុះកូនខ្មែរមានដែលធ្លាប់ដឹងទេថាអ្វីជាការ *ថតរូបដើម្បីសិល្បៈ* ស្អីគេនោះ? លោកត្រូវចាំថាកំរិតយល់ដឹងរបស់ប្រជាជនខ្មែរយើងនៅមានកំរិតទាបណាស់ មិនមែនខ្ពង់ខ្ពស់ ដូចពួកលោកខាងលិចនោះទេ កុំអាលដើរលឿនហួលជន្លោលពេក ។ លោកត្រូវដឹងថា ឱ្យតែភ្នែកមើលឃើញ គឺពិតជាមានអារម្មណ៍ បើកំរិតយល់ដឹងទាបគឺគ្រោះអាសន្នហើយ ។ ម្យ៉ាងទៀតដល់ពេលស្ត្រីជនជាតិខ្មែរម្នាក់ ពីរនាក់ ហ៊ានធ្វើដល់ថ្នាក់នោះដាក់ផ្សាយជាទូទៅទៅហើយ តើបរទេសគេនៅយល់ពីតំលៃស្ត្រីខ្មែរ តំលៃវប្បធម៌ជាតិខ្មែរដែរ ឬក៏អត់ ? ហើយចុះកូនខ្មែរវិញគិតយ៉ាងម៉េចដែរ ?

សូមកុំព្រោះតែប្រាក់ហើយនាំគ្នាបំផ្លាញតំលៃ និងព្រលឹងជាតិដ៏ល្អផូរផង់ឱ្យសោះ ពិសេសតំលៃស្ត្រីខ្មែរ តើលោកមានដែលគិតដល់តំលៃមាតា បងប្អូនស្រី កូនស្រី និងភរិយា របស់អស់លោកទេ ? បើលោកមិនគិតពីអ្នកដែលខ្ញុំរៀបរាប់ទាំងអំបាលម៉ាននេះក៏គួរគិតតំលៃស្ត្រីខ្មែរទូទៅផង ។ ទាំងបុគ្គលផ្តើមគំនិត ទាំងបុគ្គលចូលរួមសកម្មភាពអ្នកអាចធ្វើក៏បានក្នុងលក្ខខណ្ឌឯកជន តែសូមកុំប៉ះពាល់អ្នកដទៃ និងប៉ះពាល់ព្រលឹងជាតិបើមិនដូច្នោះទេគឺខុសច្បាប់ហើយ ។ អស់លោកអ្នកធ្វើនយោបាយក៏ដូចគ្នា ចង់ដណ្តើមអំណាចតាមកាសែតក៏ស្រេចតែចិត្តលោកចុះ តែដាច់ខាតសូមកុំប៉ះពាល់វប្បធម៌ខ្មែរ និងវាយបន្ថោកតំលៃស្ត្រីខ្មែរ អស់លោកត្រូវទប់ស្កាត់រឿងនេះ ។

ដូច្នេះនាងខ្ញុំសូមជំរាបអស់លោកអ្នកសារពត៌មានដែលមានការខុសឆ្គងកន្លងមកថា សូមអស់លោកពិចារណាឡើងវិញនូវប្រធានបទ និងឧត្តមគតិរបស់កាសែត ទស្សនាវដ្តីរបស់ខ្លួន ។ អស់លោកត្រូវចេះថ្លឹងថ្លែងពិចារណា និងស្រាវជ្រាវនូវរាល់អ្វីៗមានតំលៃសំរាប់យុវជន និងជាតិខ្មែរយើង ហើយម្យ៉ាងទៀតក៏គួរគិតពីតំលៃស្ត្រីខ្មែរយើង វប្បធម៌ជាតិយើងផង ។ យើងខ្ញុំមិនមែនបដិសេធអ្វីដែលជាភាពជឿនលឿនរបស់បរទេសនោះទេ ប៉ុន្តែសូមឱ្យមានព្រំដែន និងលក្ខណៈសមស្របដែលខ្មែរអាចទទួលយកបាន ហើយក៏មិនបដិសេធនូវការដែលចង់ឱ្យមានភាពចំរើនលូតលាស់របស់វប្បធម៌ជាតិយើងដែរ ប៉ុន្តែសូមឱ្យមានភាពត្រឹមត្រូវទៅតាមក្របខណ្ឌនៃជាតិយើងផង ។ មិនខ្វះទេមធ្យោបាយសំរាប់បំផុស និងបង្កើនប្រពៃណី វប្បធម៌ ទំនៀមទំលាប់របស់ជាតិ ។ ហើយបើយើងធ្វើបានពិសេសតាមរយៈសារពត៌មានជឿថាបរទេសគេនឹងស្គាល់ច្រើន ហើយអត្តសញ្ញាណជាតិយើងមិនបាត់បង់ផង ។

ជាទីបញ្ចប់នេះនាងខ្ញុំ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា លោកអ្នកជានិពន្ធនាយកកាសែត ទស្សនាវដ្តីមួយចំនួនដែលធ្លាប់មានឧត្តមគតិឃ្លាតចាកឆ្ងាយពីវប្បធម៌ជាតិនឹងវិលត្រលប់មកកាន់មាគ៌ាត្រឹមត្រូវវិញក្នុងនាមជាកុលបុត្រដែលមានឧត្តមជាតិជាក់ជាមិនខាន ។ នាងខ្ញុំសូមជូនពរដល់លោកអ្នកទាំងឡាយឱ្យបានសំរេចនូវបំណងដ៏សំខាន់ក្នុងតួនាទីពង្រីង និងពង្រឹងបណ្តាញសារពត៌មានឱ្យស្ថិតសមជាស្ថាប័នអំណាចទី៤ ពិតៗ ដើម្បីរួមចំណែកបំពេញឱ្យបាននូវប្រយោជន៍ដ៏សំរាប់ជូនជាតិមាតុភូមិដ៏កំសត់របស់យើង ។

ដោយកញ្ញា ម៉ៅ-សុខណ្ណា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ



**លិខិតមិត្តអ្នកអាន :**

# សេចក្តីព្រួយបារម្ភចំពោះលទ្ធផលនៃការ កែសំរួលឋានន្តរសក្តិកងយោធពលខេមរភូមិន្ទ

រាល់បញ្ហាដែលជាអំពើខុសឆ្គង ជ្រុលជ្រួស គ្មានការរីកចំរើននាំឱ្យមានការអន់ថយ គឺជាប្រការដែលគេត្រូវតែធ្វើវិសោធនកម្មកែសំរួលដោយខានពុំបាន ។ ហើយវាកាន់តែធ្ងន់ធ្ងរថែមទៀត ប្រសិនបើគេធ្វើស្ងៀមពុំដឹងពុំលឺទៅវិញនោះ ។ យ៉ាងណាមិញកងយោធពលខេមរភូមិន្ទ ដែលបានប្រសូត្រសារជាថ្មីម្តងទៀតនេះ គឺដោយសារការច្របាច់បញ្ចូលគ្នារវាងកងកំលាំងប្រដាប់អាវុធមកពីអតីតភាគីជំលោះខ្មែរ ដែលបានចូលរួមក្នុងការបោះឆ្នោតរៀបចំឡើងដោយ UNTAC នាខែ ឧសភា ឆ្នាំ ១៩៩៣។ កងយោធពលខេមរភូមិន្ទបានទទួលនូវអំពើខុសឆ្គងដ៏ធ្ងន់ធ្ងរមួយដែលបានបន្សល់ទុកដោយកំលាំងគណបក្សនយោបាយទាំងនោះគឺ "អតិផរណាឋានន្តរសក្តិ" ។

តើអតិផរណាឋានន្តរសក្តិជាអ្វី ? វាជាប្រការប្រឈ្យក្សណាស់ ហើយពុំអាចប្រកែកបានឡើយ ព្រោះថាក្នុងចំនួនកងយោធពលខេមរភូមិន្ទប្រមាណ ១៣០ ០០០ នាក់ ដោយគិតទាំងទ័ពខ្មោច (មានតែក្នុងបញ្ជី) ផងថ្នាក់ឧត្តមសេនីយ៍មានរហូតដល់ជាង ១២០០ នាក់ ថ្នាក់វរសេនីយ៍រាប់ម៉ឺននាក់ ។ ពោលគឺនៅតាមបណ្តាអង្គភាព ស្ថាប័នយោធានីមួយៗមានថ្នាក់នាយទាហានរងយ៉ាងតិចតួចបំផុត ហើយស្ទើរតែគ្មានសោះចំពោះពលទាហាន តើនេះពុំមែនជាអតិផរណាឋានន្តរសក្តិទេឬ ?

តើបញ្ហានេះបណ្តាលមកពីអ្វី? យើងមិនជាពិបាកយល់ទេចំពោះបញ្ហានេះ ព្រោះយើងបានដឹងរួចមកហើយថាកងយោធពលខេមរភូមិន្ទបានកើតឡើងដោយការច្របាច់បញ្ចូលគ្នា ហើយសក្តិដែលពួកគេមាននោះគឺជាសក្តិរបស់គណបក្សនយោបាយ ។ ដូច្នេះគេពុំអាចបន្ទោស ឬធ្វើការចោទប្រកាន់ចំពោះប្រមុខរាជរដ្ឋាភិបាល ឬមេ

បញ្ជាការនៃកងយោធពលខេមរភូមិន្ទបានឡើយ ។ ប៉ុន្តែគេត្រូវតែធ្វើការចោទប្រកាន់ចំពោះអ្នកដឹកនាំគណបក្សនយោបាយ និងមេទ័ពនៃគណបក្សនយោបាយជាចាំបាច់ ។

ដោយទ្រង់មានព្រះតំរិះ និងមានគំនិតដូចបានពោលខាងដើមនោះហើយ ទើបនៅថ្ងៃទី ១៨ សីហា ១៩៩៤ ប្រមុខរាជរដ្ឋាភិបាលទាំងពីរ ក្នុងឋានៈសហអគ្គមេបញ្ជាការបានចេញសេចក្តីកំណត់ស្តីពីការកែសំរួលឋានន្តរសក្តិដល់កងយោធពលខេមរភូមិន្ទ ។ ទោះបីដឹងថានោះគឺជាការកែទំរង់មួយដ៏ជ្រាលជ្រៅ និងស្មុគស្មាញយ៉ាងណាក្តី ក៏ករណីនេះប្រមុខរាជរដ្ឋាភិបាលបានចាត់ទុកជាការបន្ទាន់ មុឹងម៉ាត់បំផុតដើម្បីសំដៅពង្រឹងគុណភាពដឹកនាំប្រយុទ្ធផង និងលើកកំពស់កិត្យានុភាពរបស់កងយោធពលខេមរភូមិន្ទផង ។ លុះដល់ថ្ងៃទី ១៣ កញ្ញា ១៩៩៤ ក្នុងនាមសហប្រធានគណៈកម្មការកែសំរួលឋានន្តរសក្តិ ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងការពារជាតិបានចេញសេចក្តីណែនាំលេខ ០២_៩៤ សណេន ចុះថ្ងៃទី ១៣_៩_៩៤ ដើម្បីឱ្យគណៈកម្មការថ្នាក់ក្រោមអនុវត្តជាបន្ទាន់ដោយត្រូវបញ្ចប់ការកែសំរួលនេះជាស្ថាពរគិតទាំងអត្តសញ្ញាណប័ណ្ណ និងអត្តលេខថ្មីផងនៅថ្ងៃទី៣០ វិច្ឆិកា ១៩៩៤ ។

នេះជាមោទនភាពណាស់សំរាប់យើងជាខ្មែរ ប៉ុន្តែអ្វីដែលធ្លាប់ខុសឆ្គងដោយសារការប្រព្រឹត្តិស្មោកគ្រោកហើយដែលគេនៅតែចងចាំជានិច្ច ។ ការចងចាំបែបនេះបានប្រែក្លាយទៅជាក្តីបារម្ភបំផុតចំពោះអំពើ និងលទ្ធផលនៃការកែសំរួលឋានន្តរសក្តិនេះ ។ បញ្ហាដែលខ្លាចបំផុតនោះគឺខ្លាចពុំមានយុត្តិធម៌ គ្មានការពិនិត្យពីអតីតភាព សមត្ថភាព ទេពកោសល្យ បច្ចេកទេសជំនាញ របស់យោធិនម្នាក់ៗ ដែលជាហេតុធ្វើឱ្យគុណភាពរបស់កងយោធពលខេមរភូមិន្ទនៅតែមិនបានប្រសើរ ។

ហេតុដូចម្តេចបានជាគេព្រួយបារម្ភចំពោះគុណភាពរបស់កងយោធពលខេមរភូមិន្ទក្រោយពេលកែសំរួលឋានន្តរសក្តិ? យើងត្រូវដឹងថាជនពុករលួយ បក្សពួកនិយម គ្រួសារនិយមចាំតែឆ្លៀតឱកាសប៉ុណ្ណោះ ។ សព្វថ្ងៃនេះយើងពុំទាន់មានច្បាប់ប្រឆាំងអំពើពុករលួយនៅឡើយ ដូច្នេះវាហាក់ដូចជាឱកាសមួយដ៏ប្រសើរបំផុតសំរាប់ពួកឱកាសនិយមទាំងនោះ ។ តាមមាត្រា ២នៃសេចក្តីកំណត់របស់ប្រមុខរាជរដ្ឋាភិបាល ក្នុងនាមសហអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទបានចែងថា" រៀបចំឡើងវិញនូវឋានន្តរសក្តិនាយទាហាន នាយទាហានរង និងពលទាហានគ្រប់រូបទៅតាមមុខតំណែងរបស់យោធិនម្នាក់ៗក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ" ។ មានន័យថា នាយទាហាន នាយទហានរងណាដែលមានតួនាទីត្រូវបានទទួលឋានន្តរសក្តិជាស្វ័យប្រវត្តិទៅតាមតួនាទីដូចមានចែងនៅក្នុងសេចក្តីកំណត់លេខ ០១_៩៤ សកន ចុះថ្ងៃទី ១៥_៩_១៩៩៤ របស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិតែម្តងដោយពុំបានចែងពីសក្តិចាស់ អតីតភាព សមត្ថភាព...របស់យោធិនម្នាក់ៗឡើយ ។ ដោយឡែកនៅក្នុងគំរោងកែសំរួលឋានន្តរសក្តិថ្នាក់ជំនួយការលេខ ០២_៩៤ សកន ចុះថ្ងៃ ១៥_៩_១៩៩៤ ដែលចុះហត្ថលេខាដោយសហរដ្ឋមន្ត្រីក្រសួងការពារជាតិវិញមានចែងពីសក្តិចាស់ដែលត្រូវបានទទួលសក្តិថ្មី ប៉ុន្តែមានតែត្រឹមថ្នាក់ជំនួយការប៉ុណ្ណោះ ។

ឆ្លៀតឱកាសនេះខ្ញុំសូមបញ្ជាក់ថា មកទល់ថ្ងៃនេះហើយកែសំរួលឋានន្តរសក្តិទើបបានត្រឹមថ្នាក់វរសេនីយត្រីនៅឡើយទេ ។ ភក្តាចំបងដែលគេម្នាក់ការព្រួយបារម្ភខ្លាចនោះគឺវាមានរួចជាស្រេចទៅហើយ នេះបើតាមការឆ្លើយបញ្ជាក់របស់នាយទាហានម្នាក់នៅការិយាល័យទី១អគ្គសេនាធិការដែលសុំមិនឱ្យបញ្ចេញឈ្មោះ។ នាយទាហាន

នោះបានបញ្ជាក់បន្ថែមថាពេលនេះខ្ញុំសូមលើកយកតែមួយករណីបកបំភ្លឺ គឺដូចករណីឈ្មោះ អ_ខ បច្ចុប្បន្នជានាយទាហានជាន់ខ្ពស់ម្នាក់នៅក្រុងព្រះសីហនុ ។ ឈ្មោះ អ_ខ នោះត្រូវបានគេដឹង និងស្គាល់យ៉ាងច្បាស់ថាជាមនុស្សដែលគ្មានកិរិតវិជ្ជា គ្មានសមត្ថភាពយោធា គ្មានបទពិសោធន៏យោធា ពោលគឺគ្រាន់តែជាអតីតទាហានកីឡាដ៏តូចម្នាក់ដែលត្រូវកាត់រំសាយដោយអ៊ុនតាក់ប៉ុណ្ណោះ ។

ដូច្នេះដើម្បីកុំឱ្យការរៀបចំថ្នាក់អនុសេនីយមានភាពអយុត្តិធម៌របៀបនេះទៀត គួរឯកឧត្តម លោកអ្នកដែលមានភារកិច្ចក្នុងបញ្ហានេះត្រូវត្រួតពិនិត្យឱ្យបានហ្មត់ចត់ផង ។ ព្រោះតាមពត៌មានបានឱ្យដឹងថាបច្ចុប្បន្នការរៀបចំថ្នាក់អនុសេនីយជិតបានដល់ទីបញ្ចប់ហើយ រួចមានប្រកាសអង្គភាព និងស្លាប់នបួយចំនួនកំពុងបញ្ចូលឈ្មោះកូនរបស់ខ្លួន បក្សពួកខ្លួនដែលអ្នកទាំងនោះខ្លះមានបទពិសោធន៍យោធាដ៏តិចតួចបំផុត និងខ្លះទៀតមិនទាំងធ្លាប់បំរើការជាយោធាផងនោះ ។ ពួកនេះបានទាមជាប់កន្លែងមានតួនាទីបង្គួរៗរហូតនឹងត្រូវបានទទួលឋានន្តរសក្តិថ្មីធំជាងឋានន្តរសក្តិរបស់គណបក្សទៅទៀត ។

ប្រសិនបើករណីដូចនេះមានច្រើនមែន វាជាប្រការមួយគួរឱ្យសោកស្តាយណាស់ និងវាហាក់ដូចជាអយុត្តិធម៌ផងដែរចំពោះនាយទាហានដែលមានអតីតភាពយ៉ាងយូរលង់ ពោរពេញទៅដោយបទពិសោធន៏ និងសមត្ថភាពខ្ពង់ខ្ពស់នោះ។ ហើយប្រការដែលកាន់តែគួរឱ្យបារម្ភថែមទៀតនោះគឺគុណភាពនៃកងយោធពលខេមរភូមិន្ទរបស់យើង។

**ពីអ្នកអានម្នាក់**

✪✪✪✪✪

**លិខិតមិត្តអ្នកអាន :**

# ខ្មែរក្រហមនាំងពីរក្រុម ប្រសព្វគ្នាវិញហើយ

## *ម្តងនេះ តើក្រុមណាមួយ នឹងក្លាយជាម្ចាស់អធិរាជម្តង ឬបន្តទៅទៀត ?*

**ដោយកញ្ញា ភ្លឹន ប៊ុន្នា :**

ដោយសារតែប្រទេសខ្មែរជាប្រទេសដែលមានអំណោយផលយ៉ាងសំបូរពីរធម្មជាតិ ដូចជា ដីធ្លីមានជីវជាតិពេញទូទាំងប្រទេស មានព្រៃឈើ មានប្រេងកាត មានត្រី មានរ៉ែ មានដែក មានមាស មានពេជ្រមានត្បូង ...សុទ្ធសឹងតែវត្ថុមានតំលៃមិនអាចកំនត់បាន បន្ថែមលើនោះខ្មែរមានអាកាសធាតុអំណោយផលច្រើនដែលអាចអោយខ្មែរគេចផុតពីគ្រោះធម្មជាតិផ្សេងៗ ហើយជាពិសេសទៅទៀត ខ្មែរមានវប្បធម៌ មានអរិយធម៌រុងរឿងលើសប្រទេសនានាលើលោកនេះ ។ ដែលតាមអ្វីៗទាំងអស់នោះ អាចនិយាយបានថាខ្មែរយើងជាប្រទេសខ្លាញ់ ជាប្រទេសអ្នកមាន ជាប្រទេសដែលអាចជួយសង្គ្រោះ ជួយរំលែកទុក្ខសោកដល់ជាតិសាសន៏ដទៃបានយ៉ាងច្រើន តាមរយៈធនធានធម្មជាតិ ធនធានវប្បធម៏ដែលខ្លួនមាន ។ ដោយហេតុថាខ្មែរយើងមានលក្ខណៈបែបនេះ

ហើយ បានជាទឹកដីខ្មែរបានក្លាយទៅជាអាហារដ៏មានរសជាតិ ជាភេសជ្ជៈដ៏មានកំលាំងរបស់បរទេស ជាពិសេសប្រទេសជិតខាង មានសៀម មានយួនជាដើម ។

ចលនានៃការលេបយកទឹកដី យកកន្លែងដែលមានការអនុគ្រោះពីធម្មជាតិ យកប្រទេសដែលមានអរិយធម៌ជឿនលឿនពីសំនាក់បរទេសសៀម យួននោះបានកើតឡើងច្រើនលើកច្រើនសារ ច្រើនឆ្នាំមកហើយ ហើយពេលនេះវានៅតែមានឥទ្ធិពល មានកំលាំងយ៉ាងធំមហិមា ដែលពុំមាននរណាម្នាក់អាចដឹងច្បាស់ថា វាសនាអនាគតនៃទឹកដីខ្មែរដ៏បវរ ប្រជាជនខ្មែរដ៏ស្លូតបូតនឹងទៅជាយ៉ាងណាវិញទេ ? តាមរយៈនៃអំពើឈ្លានពានរបស់បរទេសជិតខាង ខ្មែរត្រូវបាត់បង់ស្ទើរតែអ្វីៗទាំងអស់ ទាំងទ្រព្យសម្បត្តិ ទាំងធនធានធម្មជាតិ ទាំងវប្បធម៌ ទាំងជីវិតប្រជារាស្ត្រ ទាំងទឹកដី ទាំងសមុទ្រ ទាំងទិសខាងកើត និងទិសខាងលិច ។

ចាប់តាំងពីដើមឆ្នាំ ១៩៣០មក យុទ្ធសាស្ត្រ និងយុទ្ធវិធីលេបទឹកដីពីសំនាក់យួនមានទ្រង់ទ្រាយកាន់តែធំកាន់តែសាហាវ ហើយកាន់តែគ្រោះថ្នាក់សំរាប់ខ្មែរ ។ ជាតិខ្មែរ ជាតិយួនជាច្រើនដែលជាអាយ៉ង ត្រូវបានតែងតាំងទៅតាមលំដាប់ថ្នាក់ តាមកាល និងពេលវេលាកំណត់ដើម្បីសំរេចនូវគោលបំណងរបស់គេ ។ ដូចជាមានការបង្កើតសម្ព័ន្ធភាពឥណ្ឌូចិនស្ថិតនោះ ដែលស្ថិតនៅក្រោមការដឹកនាំរបស់ខ្មោចយួនបូជីមិញ ការបង្កើតនូវបក្សសម្ព័ន្ធភាព និងចលនាផ្សេងៗដើម្បីទ្រទ្រង់មេដឹកនាំចំក្លួតខ្មែរខ្លះ ការជ្រៀតចូលទៅក្នុងប្រព័ន្ធរដ្ឋបាលរបស់ខ្មែរដើម្បីធ្វើការបំបែកបំបាក់ខ្មែរ ធ្វើការកាប់សំលាប់ខ្មែរ ។

នយោបាយនៃការរក្សាទុកអោយមានសង្គ្រាមរ៉ាំរ៉ៃ នៅកម្ពុជា ដើម្បីអោយយួនមានឱកាសសំលាប់ខ្មែរអោយខ្មែរជួយសំលាប់ខ្មែរដើម្បីអោយផុតអស់ខ្មែរពីទឹកដីខ្មែរ ហើយដើម្បីអោយដំណើរការយួនភាវូបនីយកម្មកាន់តែខិតជិតទៅដល់ការសំរេច ។ អ្វីដែលមានលក្ខណៈកាន់តែពិសេសទៅទៀតនោះ គឺការឈ្លានពានមកលើទឹកដីខ្មែររបស់យួននៅថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ដែលកាលណោះរយៈពេលតែមួយប៉ប្រិចភ្នែកប៉ុណ្ណោះ ការឈ្លានពានលេបទឹកដីពីសំណាក់យួនត្រូវបានសំរេចនៅទូទាំងប្រទេស ។

ក្រោយពីសង្គ្រាមនៅឥណ្ឌូចិនត្រូវបានបញ្ចប់ជាពិសេសនៅកម្ពុជា សម្ព័ន្ធភាព និងចលនារបស់យួនទាំងប៉ុន្មានដែលនៅសេសសល់ បូកបន្ថែមទាំងកំលាំងចាស់ថ្មីបានចូលទៅធ្វើការអុកឡុករដ្ឋបាលខ្មែរក្រហមដើម (ខ្មែរក្រហមOrigine) ធ្វើអោយខ្មែរក្រហមដើមចោសសំអាតអាពួកនេះមិនចេះអស់ មិនចេះរលស់ ហើយជាការសងសឹកវិញពីខ្មែរក្រហមក្លែងក្លាយ ពីខ្មែរក្រហមយួនវិញ គឺបានប្រលះខ្មែរអស់រាល់លាន ហើយភាគច្រើននៃខ្មែរដែលនៅសេសសល់សុទ្ធសឹងជាខ្មែរវិកលចរិក ខ្មែរដែលមិនព្រមយល់ថា ខ្លួនកំពុងរងគ្រោះព្រោះតែយួនឈ្លានពាន ។

មហាសោកនាដកម្មខ្មែរដែលបានបន្សល់ទុកនៅពេលនោះមានទំហំធំក្រៃលែង រកអ្វីមកប្រដូចមិនបានទេ ហើយក៏ពុំមាន នរណាដឹងពីជំរៅនៃទុក្ខសោកនេះបានដែរ ដ៏រាបណាគេមិនបានភ្លក្សរសជាតិនៃការឈឺចាប់ និងសេចក្តីវេទនា និងទារុណកម្មយ៉ាងព្រៃផ្សៃដែលបានកើតឡើងនៅពេលនោះ ហើយដែលបានធ្វើមកលើរាស្ត្រខ្មែរ ។ មហាសោកនាដកម្មមកលើរាស្ត្រខ្មែរ ហាក់ដូចជាបានត្រឹមតែបង្ហាញអោយមតិជាតិ និងមតិអន្តរជាតិទាំងអស់បានឮតែមលឺថា ខ្មែររងគ្រោះព្រោះខ្មែរក្រហម ។ ជាការពិតណាស់ថា ខ្មែររងគ្រោះព្រោះខ្មែរក្រហម ប៉ុន្តែត្រូវ

តែបន្តអោយបានដឹងច្បាស់ថា នរណាជាខ្មែរក្រហម ? ដោយខ្មែរក្រហមណោ ? នរណានៅពីក្រោយខ្មែរក្រហម ? ។ល។ និង។ល។

យើងគ្មានការសង្ស័យទេថា មេដឹកនាំគណៈបក្សប្រជាជនគ្រាក់ៗ(ធំៗ) នៅពេលនេះក៏ដូចជាពីមុនមក សុទ្ធតែជាមន្ត្រីខ្មែរក្រហមធ្លុមៗ(ធំៗ) ដែលមានអំណាចទាំងអស់(Sic..) ហើយសុទ្ធសឹងតែជាមន្ត្រីខ្មែរក្រហមដែលក្បត់នឹងខ្មែរក្រហមទាំងអស់(Sic..) ដោយគេបានទៅយាងទាហានយួនដែលរង់ចាំតែឱកាសហុចអោយដើម្បីប្លន់យកទឹកដីខ្មែរ មកឈ្លានពានប្រទេសខ្មែរ មកជួយសំលាប់ខ្មែរបន្ថែមទៀត ។ ដោយសារតែហេតុនេះហើយបានជាខ្មែរក្រហមយួន ដែលបានក្លាយជាមេដឹកនាំគណៈបក្សប្រជាជនគ្រាក់ៗនោះ បានទទួលជ័យជំនះពីលើរបបខ្មែរក្រហមនៅក្នុងរជ្ជកាលក្រហមខ្លួនឯង ។

ក្រោយពីបានកាន់អំណាចបន្តនៅឆ្នាំ១៩៩៣ ពួកខ្មែរក្រហមយួនបានបន្ត នយោបាយសំលាប់ខ្មែរក្រហមដើមអោយផុតពូជ តាមរយៈការបន្លសង្គ្រាម ការដាក់ខ្មែរក្រហមដើមអោយនៅក្រៅច្បាប់ជាដើម ។ល។ ទោះបីថាការបកស្រាយច្បាស់លាស់មិនទាន់ត្រូវបានធ្វើឡើងក៏ដោយ ក៏យើងអាចដឹងបានថា មានខ្មែរក្រហមពីរក្រុមបានបាក់បែកគ្នាពីមុនមក ឥឡូវនេះក្រហមទាំងពីរ គឺក្រហមយួន និងក្រហមដើមខ្លះបានមកដល់ចំណុចប្រសព្វថ្មីទៀតហើយ សួរថានរណានឹងទទួលជ័យជំនះម្តងនេះ ឬក៏បន្ថែមទៀត ? ឬក៏ថា ទាំងខ្មែរ ដែលមានសភាពធម្មតា ទាំងខ្មែរវិកលចរិកទាំងជាង ៩លាននាក់ ដែលនៅសេសសល់នឹងត្រូវបញ្ចប់ត្រឹមនេះ ? ឱ !! ខ្មែរក្រហម ? ក្រហម ! ក្រហម !

បើនៅតែយ៉ាងដូច្នេះ ជាពិសេសភាពប្រងើយកន្តើយរបស់យុវជនខ្មែរជំនាន់នេះ ទៅនឹងស្ថានភាពប្រទេសជាតិដ៏សែនអាប់អួរនៅតែមាន នៅតែអូសបន្លាយនោះ កូនចៅខ្មែរជំនាន់ក្រោយប្រាកដជានឹងក្លាយទៅជាជនជាតិភាគតិច ក្លាយទៅជាទាសករដាច់ថ្លៃ ក្លាយទៅជាមនុស្សគ្មានតំលៃសំរាប់ជនបរទេសនៅលើទឹកដីកំណើតរបស់ខ្លួនជាក់ជាមិនខាន ។

ស្លាប់និស្សិតស្រែករ:

## បញ្ហាចាស់ដែលមិនទាន់ដោះស្រាយ

នាខែសីហារៀងរាល់ឆ្នាំក្រសួងអប់រំនិងគ្រឹះស្ថានឧត្តមសិក្សាទាំង៧ បានរៀបចំការប្រលងប្រជែងជ្រើសរើសនិស្សិត(ពីសិស្សមានសញ្ញាបត្រមធ្យមសិក្សាភូមិ ២ ) អោយចូលរៀននៅឆ្នាំទី១ តាមគ្រឹះស្ថានឧត្តមសិក្សានានា ។ ចំនួនអ្នកមានសញ្ញាបត្រមធ្យមសិក្សាភូមិ២កាន់តែកើនឡើង ពីមួយឆ្នាំទៅមួយឆ្នាំមិនសមាមាត្រទៅនឹងចំនួនកៅអី( ថ្នាក់រៀន )ក្នុងសាកលវិទ្យាល័យ រឺមហាវិទ្យាល័យនីមួយៗទេ ។

សម័យប្រលងប្រជែងចូលរៀននៅឆ្នាំទីមួយក្នុងសកលវិទ្យាល័យរឺមហាវិទ្យាល័យរៀងរាល់ឆ្នាំតែងលេចចេញនូវបាតុភាពអសកម្មផ្សេងៗជាច្រើនជះឥទ្ធិពលអាក្រក់ដល់ក្រសួងអប់រំក៏ដូចជាដល់អនាគតរបស់បេក្ខជនម្នាក់ៗ ។

១_ បញ្ហាលក់ពាក្យ និងទទួលពាក្យសុំប្រលងៈ

តំលៃលក់ពាក្យសុំប្រលងប្រែប្រួលទៅតាមសកលវិទ្យាល័យ រឺមហាវិទ្យាល័យ ។ មហាវិទ្យាល័យខ្លះតំលៃលក់ពាក្យសុំប្រលងថ្លៃដែលគេនិយមហៅថាមហាវិទ្យាល័យត្រូវបាន់ ឯមហាវិទ្យាល័យមិនត្រូវបាន់តំលៃលក់ពាក្យសុំប្រលងចុះបន្តិចមិនដឹងថាក្រសួងអប់រំរឺ ក៏ធាយកមហាវិទ្យាល័យអោយយកតំលៃអ៊ីចឹង ?

ការទទួលពាក្យប្រលងមានបញ្ហាស្មុគស្មាញ ។ មហាវិទ្យាល័យមួយនោះបង្កអោយមានបញ្ហាលំបាកដល់បេក្ខជនដែលយកពាក្យប្រលងទៅដាក់ព្រោះទំរង់បែបបទពាក្យសុំប្រលងមានច្រើនដំណាក់ពេក( បោះត្រាកន្លែងនេះរឺបោះត្រាកន្លែងនោះ ) បេក្ខជនខ្លះទំរាំដាក់ពាក្យប្រលងបានស៊ីពេលវេលាយូរ ជួនកាលសរសេរខុសទិញពាក្យថ្មីមកសរសេរម្តងទៀត ជួនកាលខុសកន្លែងនេះ ខុសកន្លែងនោះបណ្តាលអោយបេក្ខជនខ្លះធុញទ្រាន់ និងរអ៊ូរទាំ ។ គត់សំគាល់ឃើញថាបេក្ខជនមកពីខេត្ត មានការលំបាកខ្លាំងណាស់ក្នុងការដាក់ពាក្យប្រលងម្តងៗដោយត្រូវឡើងចុះភ្នំពេញច្រើនសារ។ សំនូមពរសុំក្រសួងអប់រំកែប្រែទំរង់ បែបបទពាក្យសុំប្រលងកុំអោយស្មុគស្មាញពេក ។

២_ បញ្ហាដំណើរការប្រលងៈ

ដំណើការប្រលងមានបញ្ហាខ្វះខាតមួយចំនួនចាំបាច់ក្រសួងអប់រំ និងសកលវិទ្យាល័យ ឬមហាវិទ្យាល័យត្រូវបំពេញដូចជា :

- សណ្តាប់ធ្នាប់នៃការប្រលងទាំងក្នុង និងក្រៅមណ្ឌលប្រលង ។
- ការថតចំលងមេរៀន រឺ ឯកសារផ្សេងៗ ចូលមណ្ឌលប្រលង របស់បេក្ខជនម្នាក់ៗ ។
- ការបន្លំខ្លួនចូលប្រលង ជំនួសបេក្ខជនប្រលងរបស់សាច់សារលោហិតបេក្ខជន និងមិត្តភក្តិបេក្ខជន។
- ការធ្វើខ្លួនជាបេក្ខជនចូលប្រលងអង្គុយជិតបេក្ខជនពិតដោយចាំអោយបេក្ខជនពិតចំលង ។
- បញ្ហាអនុរក្ស___។ល។

៣_ បញ្ហាធ្វើវិញ្ញាសារប្រលងៈ

រៀងរាល់ឆ្នាំគណៈកម្មការកំណែវិញ្ញាសារប្រលង កំនត់ចំពោះគ្រប់ចំលើយរបស់បេក្ខជនត្រូវតែអោយដូចក្នុងបារ៉ែម ។ បញ្ហានេះក្រសួងអប់រំ ពិសេសគណៈកម្មការកំណែវិញ្ញាសារកែប្រែរបៀបនេះចោលទៅ ។ ដោយហេតុថាបេក្ខជនពូកែមានមោទនភាពចំពោះខ្លួនគេ គេគិតថាមិនបើកចាក់ ឬចំលងព្រោយយ៉ុងទេសុខចិត្តប្រើបញ្ញានិងសមត្ថភាពខ្លួនឯងពិតៗ ទើបជាប់ទៅមានន័យ។ អញ្ចឹងការសរសេរចំលើយរបស់គេគឺតាមគំនិតរបស់គេពិតៗជួនកាលទៅដូចក្នុងឯកសារ ឬមេរៀនត្រូវគ្នានឹងបារ៉ែម តែជួនកាលការសរសេរចំលើយមានចំណុចខ្លះលើសពីបារ៉ែមអញ្ចឹងទៅគ្រូកែវិញ្ញាសារពេលឃើញខុសនឹងបារ៉ែមគូសខ្វាកសំរេចអោយខុសនេះជាអំពើអយុត្តិធម៌ណាស់ចំពោះបេក្ខជនពូកែមួយភាគណានោះប្រលងចូលមហាវិទ្យាល័យធេះតែធ្លាក់ ។ យ៉ាងណាមិញចំពោះបញ្ហានេះដែរ សាស្ត្រាចារ្យម្នាក់នៅសកលវិទ្យាល័យភ្នំពេញ( មិនបញ្ចេញឈ្មោះ )បានមានប្រសាសន៍ថា គាត់បានលើកពីបញ្ហាចំលើយរបស់បេក្ខជនពូកែដែលមានចំនុចខ្លះគ្មានក្នុងបារ៉ែម ប្រាប់ទៅគណៈកម្មការកំនែវិញ្ញាសារដែរតែគេធ្វើមិនដឹងមិនលឺ

ចំពោះមតិគាត់ហើយនៅតែអនុវត្តន៍របៀបចាស់ដដែលជាដដែល ។

ចំណែកការប្រលងផ្ទាល់មាត់មួយរវាងនិស្សិត និងអស់លោកធំៗ នៅសាលាភូមិន្ទរដ្ឋបាលកន្លងមកវាក៏ជារឿងអាស្រូវដ៏ធំមួយទៅហើយ។ លោកខ្លះគ្រាន់តែឃើញ ប្រវត្តិរូបបេក្ខជននៅស្រុកជាមួយគ្នាគេបានឱ្យជាប់រួចជាស្រេចដោយមិនបាច់សួរ ។ លោកខ្លះមិនសួរមេរៀនបែរជាឯសួររឿងបក្សនយោបាយហើយប្រើវិធីបញ្ចុះបញ្ចូលមនោគមវិជ្ជាបក្សជាដើម ។ល។ បើចុះចូលជាមួយគេគឺជាប់ ។ តែបើនិស្សិតណាមិនមានខ្សែ ឬមិនចូលឆ្គងជាមួយគេ គេប្រាកដជាសួរបែកខ្ញីះធាស់ទាំងរឿងពីស្ថានព្រះឥន្ទ្រ ព្រះព្រហ្មមកទៀត ដេញសួរយ៉ាងណាទាល់តែធ្លាក់ តែបើជាប់ក៏ទក់សាច់ដែរ ។ ភាគតិចណាស់ដែលជាប់ដោយសមត្ថភាពពិតៗនោះ នេះគឺជារឿងពិតហើយមានតែនិស្សិតដែលរៀននៅទីនោះទេទើបដឹង ។

៤_ បញ្ហាហាងឆេងពេលប្រលង និង ក្រោយពេលប្រលង :

បញ្ហានេះលេចលឺសឹងតែគ្រប់ពេលប្រលងចូលមហាវិទ្យាល័យនានា វាជាការពិបាកកំណត់ណាស់ថាតើហាងឆេងនេះលេចលឺពីប្រភពណា(ក្រសួងរឺមហាវិទ្យាល័យ )តែតែងលឺគេៗគ្នាថា មហាវិទ្យាល័យត្រូវចាំន់ (ច្បាប់ សេដ្ឋកិច្ច ពាណិជ្ជសាស្ត្រ ពេទ្យ.....) ប៉ុណ្ណេះពាន់ដុល្លា ប៉ុណ្ណោះពាន់ដុល្លា រីឯមហាវិទ្យាល័យមិនសូវត្រូវចាំន់(សាកលវិទ្យាល័យភ្នំពេញ) ដូចជាមិនសូវលឺហាងឆេងសោះ ។ ធម្មតាទេនិស្សិតដែលប្រលងជាប់ខ្លះមិនដែលនិយាយថាខ្លួនជាប់ដោយស្លូកគេទេគឺសុទ្ធតែថាជាប់ដោយសមត្ថភាពគេពិតៗ ។ ប៉ុន្តែមានមួយភាគតូចទេលេចលឺដោយបុគ្គលខ្លួនឯងតែម្តង ឬតាមរយៈមិត្តភក្តិនៃបុគ្គលនោះ ។ សង្ឃឹមលើក្រសួងអប់រំនឹងចាត់វិធានការសមស្របណាមួយចំពោះបញ្ហាស្លុកចាំន់នេះ ។

៥_ បញ្ហាប្រកាសលទ្ធផល:

លទ្ធផលនៃការប្រលងជាការទន្ទឹងរង់ចាំរបស់បេក្ខជនម្នាក់ៗ ។ សុំកុំអោយមានការយឺតយូរចំពោះលទ្ធផលនេះមហាវិទ្យាល័យត្រូវចាំន់ចេញលទ្ធផលក្រោយគេទៅវិញឯមហាវិទ្យាល័យមិនត្រូវចាំន់ចេញលទ្ធផលមុនគេដូចជាចំលែកម្យ៉ាងដែរ! ។

បញ្ហាទាំងអម្បាលម៉ានដែលលើកយកមកបរិយាយនេះជាការចាប់អារម្មណ៍ និងសំណូមពរសុំក្រសួងអប់រំមេត្តាជួយដោះស្រាយបានដោយសុក្រិតនិងយុត្តិធម៌ នោះមុខមាត់ក្រសួងអប់រំនិងកេរ្តិ៍ឈ្មោះក្រសួងអប់រំនឹងលាន់លឺក្នុងអារម្មណ៍របស់និស្សិត មាតាបិតាសិស្ស និងសាធារណជនទូទៅពុំខាន ។ សូមរាជរដ្ឋាភិបាលមើលឡើងវិញឱ្យបានច្បាស់លាស់ផងលើវិស័យអប់រំជាតិនេះ ពិសេសលើការបណ្តុះបណ្តាលនិស្សិតឱ្យក្លាយទៅជាមន្ត្រីរាជការសំរាប់យកទៅបំរើការងារប្រទេសជាតិ ។

ដោយ គីម គូ និស្សិតមហាវិទ្យាល័យច្បាប់



ជ្រុងមួយនៃបញ្ហាសង្គមៈ

# អសន្តិសុខ និងអនាធិបតេយ្យឡូកឡំក្រុងភ្នំពេញ

(តចប់)

៣. <u>បញ្ហាអនាម័យៈ</u>

សេវាបំរើការក្នុងការសំអាតទីក្រុងក៏មិនមានលក្ខណៈល្អគ្រប់គ្រាន់ សំភារៈក៏មិនទំនើប កម្មករក៏មិនមានទឹកចិត្តធ្វើការងារ ឯប្រជាពលរដ្ឋមួយចំនួនធំពុំទាន់ទទួលបាននូវភាពម្ចាស់ការ និងភ្ញាក់រលឹក ។ កន្លងមកក្រុងបានធ្វើកុងត្រាជាមួយក្រុមហ៊ុនផ្សេងៗជាច្រើនមិនចេះចប់សំរាប់សេវាសំអាតក្រុងនេះ ។ ប៉ុន្តែសំរាម លាមកដ៏ច្រើនស្មុកស្មះត្រូវបានប្រជាជនចោះ ចាក់ចោល និងបន្ទោរបង់ពាសវាលពាសកាលនៅតាមទីសាធារណៈ និងដងវិថីនានាច្រើនលើសដើម ។ ចំណែកការអប់រំ ការព្រមាន និងពិន័យចំពោះការខុសឆ្គងលើបញ្ហានេះក៏មិនទាន់មានច្បាប់ ដល់អញ្ជឹងទៅមនុស្សចេះតែប្រព្រឹត្តតាមតែណាតាមតែណ ដោយគ្មានខ្មាសអៀន ។ ជាពិសេសនៅរដូវវស្សាគំនរសំរាមក្នុងទឹកសំអុយបានបង្កនូវភាពស្មោកគ្រោក ដែលបណ្ដាលឱ្យមានជំងឺឆ្លងយ៉ាងច្រើនឆ្លងដល់ប្រជាពលរដ្ឋពាសពេញទីក្រុង ។ ចំពោះបង្គន់សាធារណៈវិញក៏ក្រុងពុំមានការយកចិត្តទុកដាក់ដល់ទាល់តែសោះ ។ ការបន្ទោរបង់ពាសវាពាសកាលក៏គឺជាទំលាប់មួយយ៉ាងអាក្រក់បំផុតរបស់បងប្អូនខ្មែរនេះក៏ដោយសារតែពួកគាត់ពុំទាន់មានការអប់រំ ហើយនិយាយឱ្យចំតមិនដឹងជាឱ្យគាត់ទៅបន្ទោរបង់ឯណាបើទីក្រុងគ្មានបង្គន់សាធារណៈនោះ ។

៤. <u>បញ្ហាជនអនាថាៈ</u>

បញ្ហានេះក៏ចោទឡើងខ្លាំងនៅទីក្រុងភ្នំពេញនាបច្ចុប្បន្ននេះ ។ ជនពិការ អ្នកក្រីក្រមកពីខេត្តធ្វើជាអ្នកសុំទាន កុមារអនាថា ពួកយុវជនខុសច្បាប់ ស្រីពេស្យា និងរួមទាំងជនខិលខូចពាលាងារវាំសែមួយចំនួនធំសុទ្ធសឹងជាអ្នកដែលបង្កនូវចាតុភាពអនាធិបតេយ្យក្នុងសង្គម ។ ពួកគេបានបង្កឡើងនូវអំពើអនាចារបាត់បង់សណ្ដាប់ធ្នាប់នៅទូទាំងរាជធានីភ្នំពេញ បាត់បង់នូវប្រពៃណីដ៏ល្អរបស់ជាតិ និងបង្កើតភាពអាម៉ាស់នៅចំពោះមុខជនបរទេស ។ តាមទីវត្តអារាម តាមសួនច្បារសាធារណៈ តាមទីផ្សារ និងសំយាបផ្ទះចិន ។ល។ ត្រូវបានពួកគេចាប់យកជាចំនុចស្នាក់នៅយ៉ាងរាំហើដោយមិនគិតគូរអ្វីទាល់តែសោះ ។ ជួនកាលពួកគេបានប្រព្រឹត្តនូវអំពើអនាចារយ៉ាងមិនគួរគប្បីនៅតាមទីសាធារណៈដោយគ្មានអៀនខ្មាស ។ បញ្ហានេះវាពិតជាបានបន្ថយបន្ថោកតំលៃជាតិយើងនៅចំពោះទស្សនៈនៃជនបរទេសយ៉ាងពិតប្រាកដ ។ ចំពោះជនពិការវិញជួនកាលបានក្លាយជាអ្នកគំរាមកំហែងចំពោះមហាជន និងជាញឹកញាប់តែងមានបង្កទំនាស់ផ្ទៃក្នុងធ្វើឱ្យភ្ញាក់ផ្អើលដល់អ្នកដទៃ ។ ចំណែកឯក្មេងអនាថា និងជនគ្មានទីពឹងមួយចំនួនវិញដើម្បីតែបំពេញក្រពះក៏ក្លាយទៅជាចោរលួចឆក់ និងមួយចំនួនក្លាយខ្លួនជាចោរប្លន់តែម្តង ។

៥. <u>បញ្ហាស្រីពេស្យាចារៈ</u>

ភ្នំពេញជាសំបុកស្រីពេស្យាលេខមួយ ។ ក្នុងយុទ្ធនាការបិទបនកាលពីពាក់កណ្ដាលឆ្នាំមុនក្រុងហាក់ដូចជាអេះចំកន្លែងមេរោគរបស់មេបន និងស្រីពេស្យាតែម្តង។ តាមរូបភាពវិធានការណ៍នោះហាក់ដូចជាមានសភាពហ៊ឹកហ៊ាក់ណាស់ ។ ប៉ុន្តែវិធានការណ៍នេះហាក់ដូចជានាំមេរោគមកកណ្ដាលទីក្រុងតែម្តង ។ បនស្រីទាំងឡាយ

មិនត្រឹមតែមិនខ្លាត់ព្រាត់ចេញពីទីក្រុងទេ វាថែមទាំងរត់ចូលមកជ្រកនៅកណ្ដាលក្រុងទៅវិញ ។ មានបនមួយចំនួនទាបជាប់របងសាលារៀន វត្តអារាម និងអធិការដ្ឋាន ស្នងការដ្ឋានប៉ូលីសតែម្ដង ។ តំបន់ផ្ទះបនមួយចំនួនរេះផ្ទះខ្ទមស្លឹក ចេញផ្ទះឈើ ដល់រេះម្ដងទៀតស្រាប់តែលេចចេញផ្ទះថ្មព្រោងព្រាតទៅវិញ ។ ផ្ទះបនចេះតែកើនស្រិយូន ចេះបានចិត្តកើនឡើងៗ ហើយចេះតែស្រូបទាញស្រីខ្មែរចូលរប៉ុយៗទៅដែរ ។ ចំណែកបទល្មើសនៃការចាប់បង្ខំបោកប្រាស់ក្មេងស្រីយកទៅលក់ក៏មានសភាពគ្រើកគគ្រេងណាស់ដែរ។ តើលោកក្រុងមានដឹងបញ្ហានេះទេ ? ប្រយ័ត្នណាអស់លោក! បើតែយ៉ាងនេះគង់មានថ្ងៃណាមួយពួកជនខិលខូចចាប់កូនស្រីអស់លោកយកទៅលក់ដែរទេ ។

## ៦. បញ្ហាគេងកំណាំងប្រដាប់អាវុធ និងគ្រឿងផ្ទុះ

តាមស្ថិតិត្រួសៗបានបង្ហាញឱ្យដឹងថា នៅទូទាំងរាជធានីភ្នំពេញមានអាវុធគ្រប់ប្រភេទជាកម្មសិទ្ធិឯកជនជាង២០០០០ ដើមទៅហើយ ។ ភាពសំបូរបែបនៃគ្រឿងហឹង្សាទាំងនេះបានជុតបញ្ឆេះចរន្តគំនិតមនុស្សដែលស្ទើរតែគ្មាន និងគ្មានការអប់រំល្អឱ្យប្រព្រឹត្តផ្ទុយពីអំពើល្អ និងគោលមាគ៌ានៃច្បាប់ ។ មើលចុះអ្នកមានខ្លាយមានខ្លួង អាងស្បែកមួយចំនួនធំបានកាន់កាំភ្លើងគំរាមកំហែងដល់ជនស្លូតត្រង់ ។ ចោរប្លន់ ឃាតកម្ម ចាប់ជំរិតបាញ់ចោះអនាធិបតេយ្យ...។ល។ គឺវាកើតឡើងរាល់ថ្ងៃពាសពេញក្រុងភ្នំពេញ បង្កការគំរាមកំហែងសំលុតបំភ័យនិងប្រមាថមើលងាយផ្ដាច់ផ្ដិលជីវិតដ៏កំសត់ទុយស្រួយនៃជនដែលគ្មានកំហុស ។ បើរៀបរាប់ទៅវាមិនខ្វះទេចំពោះអ្នកដែលយកអំណាចស្បែកខ្លួងទៅប្រព្រឹត្តអំពើដូចជាចោរព្រៃទៅហើយនោះ ។ មានសមត្ថកិច្ចមួយចំនួនសាហាវជាងចោរព្រៃទៅទៀត ពួកគេកាន់កាំភ្លើងប្លន់ជនស្លូតត្រង់ កាន់កាំភ្លើងការពារបារ ការពារបនស្រីខូច បនល្បែង ។ល។ និយាយនេះមិនមែនចង់ម៉ៅរួមលើកងកំលាំងសមត្ថកិច្ចដែលល្អត្រឹមត្រូវនោះទេ ។ ប៉ុន្តែយើងដឹងហើយថាត្រីមួយត្រកតែស្អុយមួយគឺស្អុយទាំងអស់ ហើយអាគ្រឿងដែលនាំស្អុយនេះវាមានឥទ្ធិពលខ្លាំង និងឆាប់សាយភាយសម្បើមណាស់ ។

រាជរដ្ឋាភិបាលត្រូវតែពិនិត្យមើលលើបញ្ហាទាំងនេះផង ពិសេសអភិបាលក្រុងត្រូវចេះលេងធម៌ក្ដៅតាមផ្លូវច្បាប់ខ្លះ ។ មិនមែនប្រជារាស្ត្រជ្រើសរើសឱ្យធ្វើជាអ្នកមុខអ្នកការដើម្បីឱ្យខ្លួនដេកទ្រមក់ត្រាំត្រែងក្នុងឡាន វិឡាម៉ាស៊ីនត្រជាក់នោះទេគឺជ្រើសតាំងឱ្យបំរើរាស្ត្រ ។ ហើយប្រការអាក្រក់មួយត្រូវតែអ្នកដឹកនាំខ្មែរយើងបំបាត់ឱ្យខាងតែបាននោះគឺការចែកបក្សពួក អាងខ្សែ អាងខ្នងហើយចេះតែបែកឆ្វេង មិនស៊ីសង្វាក់ មិនអនុវត្តតាមតួនាទី ។ ត្រូវមើលឃើញពីទុក្ខលំបាករបស់រាស្ត្រ មិនត្រូវងើយស្មើនមើលតែកិច្ចការបក្សរៀងៗខ្លួននោះទេ ។ បើចង់ឱ្យក្រុងភ្នំពេញអភិវឌ្ឍន៍ ពិសេសជាតិទាំងមូលបានរីកចំរើន រាជរដ្ឋាភិបាលត្រូវតាំងខ្លួនជារាជរដ្ឋាភិបាលរបស់ជាតិហើយហ៊ានវះកាត់ និងដកគ្រវាត់ចោលពួកជនខិលខូច ។ សូមរាជរដ្ឋាភិបាលដឹងថា សព្វថ្ងៃនេះជួនកាលរាស្ត្រស្លូតត្រង់ខ្លាចពួកអាពតខ្មែរក្រហមជាចោរដេកក្នុងព្រៃ តិចជាងខ្លាចពួកអាពាងចោរដេកនៅក្នុងស្រុកណា!!! ពិសេសពួកអាចោរដេកក្នុងបន្ទប់មានពួកមានម៉ាស៊ីនត្រជាក់។ សូមកុំធ្វើឱ្យរាស្ត្រអស់ជំនឿណា! ឆ្នាំ១៩៩៨ជិតមកដល់ហើយ។

ដោយ ទិសេស-គតិយុត្តិ

អត្ថបទស្រាវជ្រាវ:

# អំពីជនភៀសខ្លួន និងដំណើរការបោះឆ្នោតនៅកម្ពុជា

ដោយ សេង សុផារីន

នៅឆ្នាំ ១៩៧០ គេសង្កេតឃើញមានជនភៀសខ្លួននៅលើពិភពលោកសារុបទាំងអស់ចំនួន ២.៥លាននាក់ ។ នៅរយៈពេលដប់ឆ្នាំក្រោយមកទៀត គឺនៅឆ្នាំ១៩៨០ ចំនួនជនភៀសខ្លួនពិភពលោកបានកើនឡើងរហូតដល់ទៅ ១១លាននាក់ ហើយនៅឆ្នាំ១៩៩៣ ចំនួននេះក៏បានកើនឡើងជាង ១៨.២លាននាក់ ។

ខាងក្រោមនេះ គឺជាកាលប្បវត្តិនូវព្រឹត្តិការណ៍ខ្លះៗដែលត្រូវបានគេកត់សំគាល់នៅកម្ពុជា អំពីបញ្ហាជនភៀសខ្លួន និងដំណើរការបោះឆ្នោត ការរៀបចំរដ្ឋាភិបាលកម្ពុជា គិតចាប់តាំងពីឆ្នាំពីខែសីហា ឆ្នាំ១៩៨៨ រហូតដល់ខែសីហា ឆ្នាំ១៩៩៣ ។

**នៅក្នុងឆ្នាំ ១៩៨៨ :**

- ថ្ងៃទី២៦_២៨ កក្កដា : គណៈបក្សនយោបាយកម្ពុជាទាំងបួន ដែលកំពុងច្បាំងគ្នាបានជួបប្រជុំជាលើកដំបូងរបស់ខ្លួនដែលហៅកាត់ថា JIM 1 ដើម្បីរកវិធីក្នុងការដោះស្រាយបញ្ហាជំលោះដែលបានអូសបន្លាយជាច្រើនឆ្នាំកន្លងមកហើយ ។ កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងនៅឯ បូហ្គ័រ ប្រទេសឥណ្ឌូនេស៊ី ។

**នៅក្នុងឆ្នាំ ១៩៨៩ :**

- ថ្ងៃទី ០៦_២១ កុម្ភៈ : សន្និសីទលើកទីពីរនៃភាគីជំលោះកម្ពុជា ដែលហៅកាត់ថា JIM 2 ត្រូវបានបង្កើតនៅឯទីក្រុងចាការតា ប្រទេសឥណ្ឌូណេស៊ី ។ កិច្ចពិភាក្សាបានផ្តោតជាពិសេសទៅលើចលនាបង្រួបបង្រួមជាតិ ផ្សះផ្សារជាតិ ។
- ខែកក្កដា : លោកអគ្គលេខាធិការបស់អង្គការសហប្រជាជាតិ បានតំរូវអោយអង្គការឈ្មោះថាឧត្តមក្រុមប្រឹក្សាសំរាប់ជនភៀសខ្លួន អោយទទួលបន្ទុកក្នុងការរៀបចំមាតុភូមិនិវត្តន៍នូវជនភៀសខ្លួនកម្ពុជាទាំងអស់ពីព្រំដែនខ្មែរ_ថៃ ។ ហើយលោកអគ្គលេខាធិការក៏បានលើកសំនើអោយមាននូវគំរោងព្រមព្រៀងសន្តិភាពជាសកលឡើង ។

**នៅក្នុងឆ្នាំ ១៩៩០ :**

- ថ្ងៃទី ០៣ កុម្ភៈ : សម្តេចនរោត្តមសីហនុដែលបច្ចុប្បន្ននេះជាព្រះមហាក្សត្រ និងជាប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសជាផ្លូវការនូវគោលការណ៍ស្ថាបនាជាតិឡើងវិញ ។

- ថ្ងៃទី ២១ កុម្ភៈ : សម្តេចនរោត្តមសីហនុ ហើយនិងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញនូវសេចក្តីថ្លែងការណ៍ជាសាធារណៈរួមគ្នាមួយដោយទាមទារអោយមានការបង្កើតអង្គការជាតិកំពូលមួយដែលតំណាងអោយអធិបតេយ្យភាព និងការឯកភាពជាតិកម្ពុជា ។ សេចក្តីថ្លែងការណ៍រួមគ្នានោះ ក៏បានទាមទារអោយមានផងដែរនូវការចូលរួមយ៉ាងពេញទំហឹង របស់អង្គការសហប្រជាជាតិនៅក្នុងកំឡុងពេលបណ្តោះអាសន្នមួយ រហូតដល់ចុងបញ្ចប់នៃអរិភាពរបស់ភាគីជំលោះកម្ពុជាទាំងឡាយ ។
- ថ្ងៃទី ២៦_២៨ កុម្ភៈ: ការពិគ្រោះពិភាក្សាក្រៅផ្លូវការនៅឯទីក្រុងចាការតា ប្រទេសឥណ្ឌូណេស៊ី ត្រូវបានធ្វើឡើងជាច្រើនលើកច្រើនសារ (JIM 3) ដើម្បីផ្តោតទៅលើក្រិត្យក្រមនយោបាយមួយសំរាប់ធ្វើការផ្សះផ្សារ ការបង្រួបបង្រួមជាតិ ។
- ថ្ងៃទី ២៨ សីហា : កិច្ចព្រមព្រៀង ស្តីអំពីដំណោះស្រាយជំលោះដ៏សំខាន់មួយ ត្រូវបានទទួលយកដោយភាគីជំលោះកម្ពុជាទាំងអស់ ។ កិច្ចព្រមព្រៀងនេះក៏ត្រូវបានទទួលយក និងធានាជាឯកច្ឆ័នផងដែរតាមដំណោះស្រាយលេខ ៦៦៨ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។
- ថ្ងៃទី ៩_១០ កញ្ញា : សន្និសីទមួយទៀតត្រូវបានធ្វើនៅឯទីក្រុងចាការតា ប្រទេសឥណ្ឌូណេស៊ី ។ ហើយពេលនោះភាគីជំលោះកម្ពុជាទាំងបួនក្រុមក៏បានបង្កើតចេញនូវអង្គការជាតិមួយឈ្មោះថា ឧត្តមក្រុមប្រឹក្សាជាតិ ឬហៅថា ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC) ។

**នៅក្នុងឆ្នាំ ១៩៩១ :**

- ថ្ងៃទី១៦_១៧ កក្កដា : កិច្ចប្រជុំមួយត្រូវបានប្រព្រឹត្តិធ្វើនៅទីក្រុងប៉េកាំង ប្រទេសចិន ហើយសំរេចជ្រើសរើសយកសម្តេចសីហនុធ្វើជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ។
- ថ្ងៃទី ២៧ កញ្ញា : សន្និសីទបូកសារុបដ៏ធំមួយត្រូវបានធ្វើបន្តពីកិច្ចប្រជុំនៅតាមបណ្តាប្រទេសនានាដូចជានៅទីក្រុងប៉ារីស ប្រទេសបារាំង (ថ្ងៃទី ២១_២៣ ខែធ្នូ ឆ្នាំ១៩៩០) នៅទីក្រុងប៉ាតាយ៉ា ប្រទេសថៃឡង់ (ថ្ងៃទី២៤_២៦ ខែមិថុនា និងពីថ្ងៃទី ២៦_២៩ ខែសីហា ឆ្នាំ ១៩៩១) នៅទីក្រុងចាការតា ប្រទេសឥណ្ឌូណេស៊ី (ថ្ងៃទី ៤_៦ ខែមិថុនា ឆ្នាំ ១៩៩១) និងនៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក (ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៩១) ។ នៅក្នុងសន្និសីទនេះ គតិការដ៏សំខាន់ដែលទាក់ទិនទៅនឹងក្រិត្យក្រមនយោបាយជាសាកលនៃជំលោះកម្ពុជាត្រូវបានបញ្ចប់ ។ គតិការនេះត្រូវនិងបានបង្កើតចេញនូវអជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា ដែលហៅកាត់ថា អ៊ុនតាក់ (UNTAC)

_ ថ្ងៃទី ២៣ តុលា : ពិធីចុះហត្ថលេខា និងប្រគល់លិខិតសច្ចាប័នទៅលើកិច្ចព្រមព្រៀងសន្តិភាពស្តីពីបញ្ហាកម្ពុជា ត្រូវបានធ្វើឡើងនៅទីក្រុងប៉ារីស ក្នុងសណ្ឋាគារ GORGE 5 ប្រទេសបារាំង ។

នៅក្នុងឆ្នាំ ១៩៩២ :

_ ថ្ងៃទី ២៤ មករា : កិច្ចប្រជុំជាលើកដំបូងរបស់ឧត្តមក្រុមប្រឹក្សាជាតិត្រូវបានធ្វើឡើងនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ។ កិច្ចប្រជុំបានផ្តោតជាពិសេសទៅលើការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួនកម្ពុជាចំនួនជាច្រើនម៉ឺននាក់ ពីជំរំនានានៅតាមជាយដែនខ្មែរ_ថៃ និងពីជំរំនៅប្រទេសផ្សេងៗទៀតដូចជា ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ។ល។ ការធ្វើមាតុភូមិនិវត្តន៍មកកាន់ ប្រទេសកម្ពុជាវិញ ត្រូវធ្វើនៅលើគោលការណ៍សេរី និងដោយលក្ខណៈស្ម័គ្រចិត្តទៀតផង ។

_ ថ្ងៃទី ២៧ មីនា : កងថ្មើរជើងដែលមានគ្នាចំនួន ៨៥០នាក់ របស់អ៊ិនឌា បានមកដល់ទីក្រុងបាត់ដំបងដើម្បីផ្តល់នូវការការពារសុវត្ថិភាព និងសន្តិសុខដល់ក្បួនកុងវ៉័រជនមាតុភូមិនិវត្តន៍លើកទីមួយ ពីព្រំដែនខ្មែរ_ថៃ ។

_ ថ្ងៃទី ៣០ មីនា : ក្បួនកុងវ៉័រនៃជនមាតុភូមិនិវត្តន៍កម្ពុជាលើកទីមួយបានឆ្លងកាត់ព្រំដែនខ្មែរ_ថៃឆ្ពោះទៅកាន់ខេត្តបាត់ដំបង ។ ក្បួនកុងវ៉័រលើកទីដំបូងនេះ បានដឹកនាំជនភៀសខ្លួនចំនួន ៥២៧នាក់ ដែលសំរេចធ្វើមាតុភូមិនិវត្តន៍តាមគោលការណ៍ស្ម័គ្រចិត្តពីជំរំចំនួន ៦ កន្លែង ។

_ ថ្ងៃទី ០២ មេសា : ដោយមានកិច្ចប្រជុំរវាងឧត្តមស្នងការជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ និងមន្ត្រីនៃរដ្ឋកម្ពុជា មានកិច្ចព្រមព្រៀងមួយត្រូវបានអនុម័តឡើងដើម្បីដំនើរការមាតុភូមិនិវត្តន៍ជនភៀសខ្លួនកម្ពុជាពីបណ្តាប្រទេសផ្សេងទៀតក្រៅពីប្រទេសថៃឡង់ ។

_ ថ្ងៃទី ២៤ មេសា : ក្រុមជនភៀសខ្លួនកម្ពុជាលើកទីមួយ បានចេញដំណើរពីប្រទេសឥណ្ឌូណេស៊ីតាមយន្តហោះចូលមកកាន់ប្រទេសខ្មែរ ។

_ ថ្ងៃទី ២៧ មេសា : មានការបើកជាផ្លូវការនូវមជ្ឈមណ្ឌលទទួលជនភៀសខ្លួនដែលនឹងត្រូវធ្វើមាតុភូមិនិវត្តន៍មកដល់ទីក្រុងភ្នំពេញ ពីបណ្តាជំរំនានា ។

_ ថ្ងៃទី ៣០ មេសា : ក្បួនកុងវ៉័រដោយរថយន្តយានលើកទីមួយឈ្មោះថា SISOPHON EXPRESS បានមកដល់ទីក្រុងភ្នំពេញដោយនាំមកជាមួយនូវជនមាតុភូមិនិវត្តន៍ចំនួន ៦១២នាក់ ។ រថភ្លើងត្រូវដំណើរការឥតឈប់ឈរក្នុងការដឹកជញ្ជូនអ្នកដំណើរ ពីស្វាយស៊ីសុផុនមកភ្នំពេញ រៀងរាល់បួនថ្ងៃម្តង រហូតដល់ចុងបញ្ចប់នៃកិច្ចប្រតិបត្តិការ ។

( នៅមានត )

**នំពាក្យទី:**

# ត្រកួន កញ្ឆែត

ត្រកួន កញ្ឆែត  បោះទងហក់ស្វែត  ប្រជែងទិត្ថា  ផណ្ដើមលូតមុន
ភ្លេចគិតគណនា  ខ្លាចណាស់ភ័យា  ក្រែងមិនធំមុន ។
ត្រកួន កញ្ឆែត  ម្នាក់ៗស្ទុះភ្លែត  លែងគិតស៊ុយស៊ុន  ផណ្ដើមយកឈ្នះ
មើលឃើញខ្លួនគ្រាន់  ផណ្ដើបអាចម៍មាន់  ធីមនុស្សដាក់ឱ្យ ។
ត្រកួន កញ្ឆែត  ផណ្ដើបស៊ីឆ្អែត  គ្មានគិតមុខក្រោយ  មួយផណ្ដើមមួយ
មិនផ្ទេសបណ្ដោយ  ពួយអស់ដៃហើយ  គ្មានគិតផងគ្នា ។
ត្រកួន កញ្ឆែត  ភ្លេចអស់កំណើត  ពូជពង្សវង្សា  ផណ្ដើមកាប់ចាក់
ស្ទើរស្លាប់អាត្មា  មិនបានគិតថា  មនុស្សបោកពួកវា ។
លុះធំលូតវែង  ត្រកួនកញ្ឆែង  អួតប្រាប់គេថា  ខ្លួនឈ្នះកញ្ឆែត
សាច់ឈាមសត្ថា  ឯកញ្ឆែតវា  ខ្លួនខ្មៅក្រងិត ។
រីឯកញ្ឆែត  បោះទងដើបភ្លែត  ឆ្លើយមិនចាច់គិត  ឯងសតែសាច់
តែគ្មានគំនិត  អញខ្មៅមែនពិត  រសជាតិឈ្ងុយឆ្ងាញ់ ។
ប្រជែងទៅមក  តំរាមសង្សក  រករឿងឈ្លោះបាញ់  ភ្លេចគិតឯមនុស្ស
ឈរសំលក់ខ្លាញ់  ទាំងឈ្នះទាំងចាញ់  អញត្លិចមកធី ។
ត្រកួន កញ្ឆែត  បើយើងរិះគិត  មិនខុសអំពី  មនុស្សខ្មែរសព្វថ្ងៃ
ផណ្ដើមគ្នាស៊ី  ផណ្ដើមស្រីញី  ផណ្ដើមគ្នាធំ ។
មានរឿងអាក្រក់  ជាតិកករល្អក់  មិនគិតជំនុំ  មិនគិតរួបរួម
ដឹងត្រឹមអញធំ  គ្មានផ្លូវទេកុំ  មកហំអាវ៉ា ។
ប្រទូស្តគ្នាឯង  បែកខ្ញែកផ្លូវផ្សេង  ភ្លេចគិតបច្ចា  ចូលមកទន្ទ្រាន
រុករានរដ្ឋា  គង់មានថ្ងៃណា  ខ្ទីទាំងអស់គ្នា ។
កុំឃើញជាតិយំ  ម្នាក់ជួយម្នាក់កុំ  ចាក់រុកពានពារ  ស៊កសៀតផ្លែផ្កា
ចាំមកពីវា  ឱ្យរាស្ត្រវេទនា  ដោយសារគ្នាឯង ។
នៅមិនស្ងប់សោះ  ម្នាក់ប៉ុនចាញ់បោះ  ម្នាក់ញៀះជាល្បែង  ហែកហួរថែមថយ
ខ្មែរមិនអង្វែង  រស់តែគ្នាប្រែង  ឯរាស្ត្រងាប់អស់ ។

ដោយ ឌឹម_ទី
មហាវិទ្យាល័យគរុកោសល្យ